ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# ផែនការសកម្មភាពជាតិ
# ស្តីពី
# ការគាំពារនិងអភិវឌ្ឍន៍កុមារតូច
# ២០១៤ - ២០១៨

បានទទួលការឯកភាពពី **គ.ជ.គ.ក.**

នាសម័យប្រជុំថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤

# អារម្ភកថា

ប្រទេសកម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍមូលធនមនុស្សដែលប្រកបដោយគុណភាព សមត្ថភាពនិងគុណធម៌ ដែលជាកត្តាគន្លឹះសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេសក្នុងពេលបច្ចុប្បន្ននិងអនាគត។ ក្នុងបរិបទនេះការគាំពារនិងអភិវឌ្ឍន៍កុមារតូច បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំនិងមិនអាចខ្វះបានក្នុងការអភិវឌ្ឍន៍ធនធានមនុស្សដោយផ្តើមចេញពីការគាំទ្រការអនុវត្តតាមបែបពហុវិស័យបញ្ចូលគ្នា។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញគោលនយោបាយជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូច ហើយទទួលបានការឯកភាពក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០។

ដើម្បីអនុវត្តយុទ្ធសាស្រ្តទាំង៩ ក្នុងគោលនយោបាយជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូចឱ្យទទួលបានជោគជ័យ ចាំបាច់ត្រូវមានផែនការសកម្មភាពជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូចមួយដែលមានលក្ខណៈប្រាកដប្រជានិងអាចអនុវត្តបាន។ ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៤-២០១៨ បានរៀបចំឡើងដោយមានការចូលរួមពិគ្រោះយោបល់ទូលំទូលាយជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីធានាបានការបំពេញមុខងារ តួនាទី ភារកិច្ច និងការទទួលខុសត្រូវក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។

ផែនការសកម្មភាពជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៤-២០១៨ ពិតជារួមចំណែកក្នុងការសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា ផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិឆ្នាំ២០១៤-២០១៨ ផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៤-២០១៨ និងផែនការយុទ្ធសាស្រ្តវិស័យពាក់ព័ន្ធដទៃទៀត។ ផែនការសកម្មភាពជាតិនេះនិងកម្មវិធីកំណែទម្រង់នានា បានកសាងឡើងក្នុងទស្សនៈផ្សារភ្ជាប់ទំនាក់ទំនងគ្នារវាងគោលនយោបាយ យុទ្ធសាស្រ្តអនុវត្ត និងធនធានហិរញ្ញវត្ថុ។

សកម្មភាពអាទិភាពទាំងឡាយដែលបានដាក់បញ្ចូលក្នុងផែនការសកម្មភាពជាតិនេះរួមមានយន្តការនិងការងាររៀបចំក្របខណ្ឌគតិយុត្ត ការកែលម្អយន្តការពិនិត្យតាមដាននិងវាយតម្លៃ ការអភិវឌ្ឍសមត្ថភាព ការពង្រីកសេវាអប់រំនិងថែទាំសុខភាពដល់ស្ត្រីនិងកុមារតូច ការផ្តល់ការអប់រំមូលដ្ឋានឱ្យបានទាន់ពេលវេលាដល់កុមារតូច ដោយផ្តោតជាពិសេសលើកុមាររងគ្រោះ កុមារងាយរងគ្រោះនិងកុមារដែលមានជីវភាពក្រីក្រ។ ការលើកទឹកចិត្តនិងការអភិវឌ្ឍសមត្ថភាពមន្ត្រីពាក់ព័ន្ធគ្រប់កម្រិតទាំងអស់ក៏ត្រូវបានដាក់បញ្ចូលផងដែរ។

ផែនការសកម្មភាពជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូចឆ្នាំ២០១៤-២០១៨ បានរៀបចំឡើងតាមយន្តការការងារច្បាស់លាស់ តាមរយៈការស្រាវជ្រាវ កិច្ចពិគ្រោះយោបល់ និងការចូលរួមយ៉ាងទូលំទូលាយពីសំណាក់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ផែនការសកម្មភាពជាតិនេះ បំពេញតួនាទីជាផែនទីតម្រង់ទិសសម្រាប់អនុវត្តរាល់សកម្មភាពពាក់ព័ន្ធនឹងកិច្ចគាំពារនិងអភិវឌ្ឍន៍កុមារតូចប្រកបដោយប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៤

**ប្រធានគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច**

## មាតិកា


អារម្ភកថា ............................................................ 1

មាតិកា ............................................................ 2

១. សារបាន ............................................................ 1

១.១ គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ............................................................ 2

១.២ ស្ថានភាព ............................................................ 3

១.៣ បញ្ហាអាទិភាព ............................................................ 9

២. យុទ្ធសាស្ត្រ ............................................................ 12

យុទ្ធសាស្ត្រទី ១ ............................................................ 13

យុទ្ធសាស្ត្រទី ២ ............................................................ 15

យុទ្ធសាស្ត្រទី ៣ ............................................................ 16

យុទ្ធសាស្ត្រទី៤ ៖ ............................................................ 18

យុទ្ធសាស្ត្រទី ៥ ............................................................ 18

យុទ្ធសាស្ត្រទី៦ ............................................................ 19

យុទ្ធសាស្ត្រទី៧ ............................................................ 20

យុទ្ធសាស្ត្រទី ៨ ............................................................ 22

យុទ្ធសាស្ត្រទី ៩ ............................................................ 23

៣. ផែនការសកម្មភាព ............................................................ 26

៤. គម្រោងចំណាយ ............................................................ 50

៥.ការប្រមូលធនធានគាំទ្រការអនុវត្តផែនការសកម្មភាព ............................................................ 51

៥.១ នីតិវិធីនៃការប្រមូលធនធាន ............................................................ 52

៥.២ ការចូលរួមនិងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ ............................................................ 52

៦. ការពិនិត្យតាមដាន និងការវាយតម្លៃ ............................................................ 55

ការពិនិត្យផលប៉ះពាល់ ............................................................ 55

ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាព ............................................................ 55

ការពិនិត្យតាមដានការអនុវត្តកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូចតាមវិស័យ ............................................................ 55

ការរៀបចំឯកសារឧបសម្ព័នផែនការសកម្មភាពជាតិ ............................................................ 56

៧. សេចក្តីសន្និដ្ឋាន ............................................................ 58



# ១. សារបាន

## ១. សារថ្នាន

គោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍន៍កុមារតូច ទទួលបានការអនុម័តជាផ្លូវការពីគណៈរដ្ឋមន្ត្រីនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១០។ គោលនយោបាយនេះបានរៀបចំឡើងក្រោមការដឹកនាំសម្របសម្រួលដោយក្រសួងអប់រំ យុវជន និងកីឡា និងមានកិច្ចសហការពេញលេញពីក្រសួងពាក់ព័ន្ធចំនួន ១០ ផ្សេងទៀត ដែលកំពុងបំពេញការងារពាក់ព័ន្ធសេវាគាំពារនិងអភិវឌ្ឍកុមារតូច។ ក្រសួងពាក់ព័ន្ធទាំង១០ នោះរួមមាន (១)ក្រសួងសុខាភិបាល (២)ក្រសួងមហាផ្ទៃ (៣)ក្រសួងកិច្ចការនារី (៤)ក្រសួងព័ត៌មាន (៥)ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៦)ក្រសួងអភិវឌ្ឍន៍ជនបទ (៧)ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៨)ក្រសួងផែនការ (៩)ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង(១០)ក្រសួងបរិស្ថាន។

ឈរលើមូលដ្ឋានគោលនយោបាយខាងលើក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច របស់ប្រទេសកម្ពុជារយៈពេល ៥ ឆ្នាំ ចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៨ ដែលមានលក្ខណៈរួមបញ្ចូលគ្នានិងមានការសម្របសម្រួលជាមួយគ្នាទៅវិញទៅមកពីគ្រប់វិស័យដែលពាក់ព័ន្ធ។ ផែនការសកម្មភាពជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូចនេះ នឹងចូលរួមចំណែកដោយផ្ទាល់ចំពោះការសម្រេចឱ្យបាននូវចំណុចដៅនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាដោយផ្តោតការយកចិត្តទុក ដាក់លើការបង្កើនគុណភាពសេវា និងពង្រីកភាពគ្របដណ្តប់នៃសេវាគាំពារនិងអភិវឌ្ឍកុមារតូចឱ្យបានឆាប់រហ័ស។

ផែនការសកម្មភាពជាតិនេះមានគោលបំណងផ្តល់នូវការគាំទ្រចំពោះការគាំពារ និងអភិវឌ្ឍកុមារតូចពហុវិស័យបញ្ចូលគ្នា ដល់កុមារតូចចាប់ពីកកំណើតដល់ក្រោម៦ឆ្នាំ រួមនិងមាតាបិតា ឬអាណាព្យាបាល ពាក់ព័ន្ធនឹងការចិញ្ចឹមកូន ការថែទាំកូន ការភ្ញោចដើម្បីជួយកូនឱ្យទាន់ពេលវេលា ការផ្តល់អាហារូបត្ថម្ភ ការគាំពារសុខភាព ការអប់រំ និងអនាម័យ សំដៅការពារនិងលើកកម្ពស់ការអភិវឌ្ឍផ្នែកសុខភាព និងរាងកាយ អភិវឌ្ឍន៍ផ្នែកសីលធម៌និងវប្បធម៌ អភិវឌ្ឍន៍ផ្នែកសង្គម និងអារម្មណ៍ និងអភិវឌ្ឍន៍ផ្នែកបញ្ញានិងការគិតរបស់កុមារ ជាពិសេសកុមារមកពីគ្រួសារក្រីក្រ ជនជាតិដើមភាគតិច និងកុមារមានពិការភាព តាមរយៈ ៖

- ការប្រែក្លាយវត្ថុបំណងគោលនយោបាយជាតិស្តីពី ការគាំពារនិងអភិវឌ្ឍកុមារតូច ឱ្យទៅជាសកម្មភាពប្រតិបត្តិ
- ការបង្កើតក្របខណ្ឌការងារសម្រាប់ជំរុញការគាំពារនិងអភិវឌ្ឍន៍កុមារតូច
- ការរៀបចំក្របខណ្ឌយន្តការការងារ និងការសម្របសម្រួលការគាំពារនិងអភិវឌ្ឍន៍ កុមារតូច
- ការកៀរគរធនធានសម្រាប់គាំទ្រដល់សកម្មភាពគាំពារនិងអភិវឌ្ឍកុមារតូច
- ការបង្កើតក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃរួមគ្នាអំពីសកម្មភាពគាំពារ និងអភិវឌ្ឍកុមារ តូច។

## ១.១ គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច

ចក្ខុវិស័យស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច គឺកុមារតូចទាំងអស់ចាប់ពីកកំណើតរហូតដល់អាយុក្រោម ៦ ឆ្នាំ ត្រូវទទួលបានសេវាគាំពារនិងអភិវឌ្ឍ ជាពិសេសកុមារតូចរងគ្រោះកុមារតូចងាយរងគ្រោះ និងក្រខ្សត់ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនិងគោលដៅ របស់គោលនយោបាយជាតិស្តីពី ការគាំពារនិងអភិវឌ្ឍន៍កុមារតូចបានលើកឡើងនូវផលសម្រេចចុងក្រោយគឺ ៖

១. ស្ត្រីទាំងអស់ទទួលបាននូវសេវាថែទាំនិងសេវាអប់រំសុខភាព ព្រមទាំងអាហារូបត្ថម្ភនៅពេលមានផ្ទៃពោះ។
២. កុមារតូចទាំងអស់ទទួលបានការចុះបញ្ជីកំណើត ការថែទាំពិនិត្យសុខភាពជាប្រចាំ ថ្នាំបង្ការ អាហារូបត្ថម្ភគ្រប់គ្រាន់ និងទទួលបានការហាត់រៀនពីដំបូង។
៣. កុមារតូចទាំងអស់មានលក្ខណៈត្រៀមជាស្រេចដើម្បីចូលរៀនថ្នាក់ទី ១ នៅអាយុ ៦ឆ្នាំ។
៤. បុគ្គលិកបច្ចេកទេស អ្នកថែទាំកុមារតូច មាតាបិតានិងអ្នកអាណាព្យាបាលដែលមានចំណេះដឹងគ្រប់គ្រាន់ លើការគាំពារនិងអភិវឌ្ឍន៍កុមារតូច។
៥. គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធទាំងអស់ សហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងការគាំពារនិងអភិវឌ្ឍន៍កុមារតូច។
៦. កុមារតូចចាប់ពីពេលប្រសូតរហូតដល់ពេលចូលរៀន មានការរីកចម្រើនផ្នែករាងកាយ ចំណេះដឹង ប្រាជ្ញានិងអារម្មណ៍នៅតាមផ្ទះរបស់ខ្លួន ព្រមទាំងតាមមណ្ឌលនានាដែលផ្តល់សេវាសុខភាព អាហារូបត្ថម្ភ ការអប់រំប្រកបដោយគុណភាព និងនិរន្តរភាព។

គោលនយោបាយជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចមានខ្លឹមសារសំខាន់ដូចខាងក្រោម៖

១. ធានាការផ្តល់សេវាសម្រាប់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ចាប់ពីកកំណើតរហូតដល់អាយុក្រោម ៦ឆ្នាំ
២. ធានាឱ្យកុមារតូចមានការគាំពារនិងអភិវឌ្ឍន៍ពេញលេញលើគ្រប់ផ្នែក
៣. ធានាឱ្យក្រសួង ស្ថាប័នសាធារណៈ និងសង្គមស៊ីវិលដែលពាក់ព័ន្ធទាំងអស់សហការគ្នាសម្រាប់ការគាំពារនិងអភិវឌ្ឍន៍កុមារតូច។

## ១.២ ស្ថានភាព

ក្នុងជំរឿនប្រជាជនឆ្នាំ២០១៣ ប្រទេសកម្ពុជាមានប្រជាជនសរុបប្រមាណ ១៤,៧ លាននាក់ មានអត្រាកំណើនប្រជាជនប្រចាំឆ្នាំ ១,៤៦ ភាគរយ និងមានអត្រាបង្កើតកូនសរុប ២,៨ ភាគរយ (អង្កេតចន្លោះជំរឿន)។ ប្រជាជន ៧៨,៦ ភាគរយ ភាគច្រើនរស់នៅតាមទីជនបទ។ ក្រុមជនជាតិភាគតិចមានប្រមាណជា ១០ ភាគរយ នៃចំនួនប្រជាជនសរុប។ ធនាគារពិភពលោកបានប៉ាន់ស្មានថាក្នុងឆ្នាំ២០១០ ចំនួនកុមារកម្ពុជាអាយុពី ០ ដល់ក្រោម ៦ ឆ្នាំ មានពី ៣៦១.០០០ នាក់ ដល់ ១.៦១១.០០០ នាក់ ស្មើនឹង ១១,១ ភាគរយ នៃចំនួនប្រជាជនសរុប។

ចាប់ពីឆ្នាំ២០១២ ចំណូលផលិតផលក្នុងស្រុកសរុប(ផសស) ជាមធ្យមរបស់ប្រជាជនម្នាក់ៗ មានកម្រិតលើស ១.០០០ ដុល្លារសហរដ្ឋអាមេរិក។ ចំណូលនេះបានកើនឡើងជិត៥ដងនៃចំណូល ផសស របស់ប្រជាជនម្នាក់ៗកាលពីមួយទសវត្សរ៍កន្លងទៅ។ តាមរយៈនិន្នាការកើនឡើងនេះ កម្ពុជាអាចចាកចេញពីបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួចក្នុងរយៈពេលដ៏ខ្លីខាងមុខ។ ប្រជាជនដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រដែលកំណត់ត្រឹម ០,៩៣ ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយថ្ងៃ មាន ២២,៩ ភាគរយ នៅឆ្នាំ២០០៩ ហើយបន្តធ្លាក់ចុះនៅ១៨,៩ ភាគរយនៅឆ្នាំ២០១២ (ក្រុមការងារជាតិសម្រាប់វាស់វែងភាពក្រីក្រនៅកម្ពុជាក្រសួងផែនការ) ខណៈដែលចំណុចដៅរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាបានកំណត់ ១៩,៥ ភាគរយ នៅឆ្នាំ២០១៥។

អត្រាអក្ខរកម្មមនុស្សពេញវ័យចាប់ពីអាយុ ១៥ ឆ្នាំ ដល់ ៤៥ ឆ្នាំមាន ៨៧,០៥ ភាគរយ នៅក្នុងឆ្នាំ២០១៣-២០១៤ ហើយចំណុចដៅត្រូវបានដាក់ចេញសម្រាប់ឆ្នាំ ២០១៧-២០១៨ គឺ ៩០,៥៥ ភាគរយ ( ផែនការយុទ្ធសាស្រ្តវិស័យអប់រំឆ្នាំ២០១៤-២០១៨)។ មាតាបិតាមួយចំនួនមានជីវភាពក្រីក្រដោយសារតែគាត់ជាអ្នកដែលមិនចេះអក្សរ ឬ ទើបចេះអក្សរតិចតួច។

បើទោះបីជាស្ថានភាពសុខភាពប្រជាជនជាទូទៅនៅក្នុងប្រទេសកម្ពុជា មានភាពល្អប្រសើរជាងមុនក៏ដោយ អាយុរំពឹងទុកមានត្រឹមតែ ៦១ ឆ្នាំ តែប៉ុណ្ណោះ គឺ ៦០,៥ ឆ្នាំ សម្រាប់បុរស និង ៦៤,៣ ឆ្នាំ សម្រាប់ស្រ្តី (យូនីសេហ្វ ២០០៨) បើធៀបនឹងអាយុជាមធ្យម ៧៨ ឆ្នាំនៅតាមបណ្តាប្រទេសឧស្សាហកម្មនានា។ ចន្លោះពីឆ្នាំ២០០០ ដល់ ២០១០ ប្រទេសកម្ពុជាបានសម្រេចនូវវឌ្ឍនភាពជាច្រើនក្នុងការលើកកម្ពស់សុខភាពកុមារនៅក្នុងប្រទេសរបស់ខ្លួន។ អត្រាមរណភាពទារកមាន ការថយចុះពី ៩៥ មក ៤៥ ករណី ក្នុង ១ ០០០ កំណើតរស់ ហើយអត្រាមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ មានការថយចុះពី ១២៤ មក ៥៤ ករណីក្នុង ១.០០០ កំណើតរស់ (ការអង្កេតប្រជាសាស្រ្តនិងសុខភាពនៅកម្ពុជា CDHS ២០១០) ដែលនាំឱ្យប្រទេសកម្ពុជាស្ថិតលើមាគ៌ាត្រឹមត្រូវក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ទី៤ របស់ខ្លួនពាក់ព័ន្ធនឹងការកាត់បន្ថយអត្រាមរណភាពកុមារ។ វឌ្ឍនភាពនៃការកាត់បន្ថយអត្រាមរណភាពកុមារនេះ កើតឡើងជាចម្បងដោយសារតែការអនុវត្តការងារបានយ៉ាងល្អនៃកម្មវិធីជាតិផ្តល់ថ្នាំបង្ការ ជោគជ័យនៃការផ្សព្វផ្សាយ

អំពីការបំបៅកូនដោយទឹកដោះម្ដាយ (ការបំបៅកូនដោយទឹកដោះម្ដាយក្នុងអំឡុងមួយម៉ោងដំបូងក្រោយសម្រាល មានការកើនឡើងពី ១១ ភាគរយ ដល់ ៦៥,២ ភាគរយ និងការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់មានការកើនឡើងពី ១១,៤ ភាគរយ (CDHS ២០០០) ដល់ ៧៣,៥ ភាគរយ (CDHS ២០១០) និងកត្តានានា ដែលស្ថិតនៅខាងក្រៅវិស័យសុខាភិបាលដូចជា ការកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់ការអប់រំ និងមានផ្លូវថ្នល់ល្អប្រសើរជាងមុនជាដើម។

បញ្ហាកង្វះអាហារូបត្ថម្ភនៅតែជាបញ្ហាធំមួយនៅក្នុងប្រទេសកម្ពុជា បើទោះបីជាមានការកែលម្អនៅក្នុងរយៈពេល ៥ ឆ្នាំ ដំបូងនៃទសវត្សរ៍នេះក៏ដោយ។ ក្នុងឆ្នាំ២០១០ ភាពក្រិនរបស់កុមារស្ថិតក្នុងសភាពទ្រឹងក្នុងរង្វង់ ៤០ ភាគរយ ដែលប្រទេសកម្ពុជាត្រូវបានចាត់ទុកជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានប្រេវ៉ាឡង់កុមារក្រិនខ្ពស់ជាងគេនៅក្នុងតំបន់។ ជាមួយនោះ ភាពស្គមស្គាំងរបស់កុមារបានថយចុះពី ១៧ ភាគរយ នៅឆ្នាំ ២០០០ មកនៅត្រឹម ៨ ភាគរយ នៅឆ្នាំ ២០០៥ ប៉ុន្តែកើនឡើងដល់ ១០,៩ ភាគរយ នៅឆ្នាំ(CDHS ២០១០) ។

កង្វះមីក្រូសារជាតិនៅតែកើតឡើងជាទូទៅ ហើយភាពស្លេកស្លាំងតែងតែកើតមានក្នុងចំណោមស្ត្រីមានផ្ទៃពោះ ៥២,៧ ភាគរយ ស្ត្រីក្នុងវ័យបន្តពូជ ៤៤,៤ ភាគរយ និងកុមារ ៥៥ ភាគរយ (CDHS ២០១០) ។ បន្ទាប់ពីមានការកែលម្អមួយចំនួនរួចមក ការផ្ដល់វីតាមីនអា បន្ថែមដល់កុមារអាយុពី ៦ ដល់ ៥៩ ខែបានដល់កម្រិត ៧១ ភាគរយ។

ជារៀងរាល់ឆ្នាំមានកុមារប្រមាណ ២.៣០០ នាក់ បានបាត់បង់ជីវិតដោយសារជំងឺរាករូស។ បញ្ហាកង្វះអាហារូបត្ថម្ភ ធ្វើឱ្យជំងឺរាករូសកាន់តែកើតឡើងញឹកញាប់ជាងមុននិងអូសបន្លាយពេលយូរជាងមុន។ នៅតាមតំបន់ជនបទប្រជាពលរដ្ឋ ២៤,៧ ភាគរយ ប៉ុណ្ណោះដែលមានបង្គន់ប្រើប្រាស់ ៥៣,១ ភាគរយ មានទឹកស្អាតសម្រាប់បរិភោគ។ នៅពេលដែលអនាម័យនិងការផ្គត់ផ្គង់ទឹកស្អាតមានកម្រិតទាបបែបនេះ ប្រទេសកម្ពុជាតែងតែប្រឈមនឹងជំងឺឆ្លងដែលអាចបង្កឱ្យមានជំងឺកាន់តែច្រើននៅក្នុងបរិស្ថានជុំវិញ។ កុមារដែលមានជំងឺដោយសារតែផឹកទឹកមិនស្អាតនិងមានអនាម័យមិនគ្រប់គ្រាន់ មានបញ្ហាខ្សោយពោះវៀនដែលធ្វើឱ្យពួកគេមានការពិបាកក្នុងការស្រូបយកសារធាតុចិញ្ចឹមនានា។ កុមារក្រិនរៀនមិនសូវពូកែឡើយ ដោយសារតែពួកគេទទួលរងការខូចខាតប្រព័ន្ធសម្រាប់ស្រូបយកចំណេះដឹងនៅក្នុងរយៈពេលវែង។

ការប្រើប្រាស់មធ្យោបាយពន្យារកំណើតនៅមានកម្រិត។ ក្នុងឆ្នាំ២០០៧ មនុស្សពេញវ័យត្រឹមតែ ២៧ ភាគរយ ប៉ុណ្ណោះ បានប្រើប្រាស់មធ្យោបាយពន្យារកំណើត ការថែទាំផ្ទៃពោះមិនបានជិតដល់និងអាហារូបត្ថម្ភមិនគ្រប់គ្រាន់ក្នុងពេលមានផ្ទៃពោះ។ ក្នុងឆ្នាំ ២០០៨ ស្ត្រីមានផ្ទៃពោះបានទៅពិនិត្យផ្ទៃពោះជាមួយបុគ្គលិកសុខាភិបាលជំនាញ ចាប់ពី ២ ដងឡើងទៅមាន ៨១ ភាគរយ ហើយស្ត្រីមានផ្ទៃពោះ ៨៩ ភាគរយ បានទៅពិនិត្យផ្ទៃពោះយ៉ាងហោចណាស់ ១ ដង មុនពេលសម្រាល។ ក្នុងឆ្នាំ២០១០ ស្ត្រីមានផ្ទៃពោះត្រឹមតែ ៥៩ ភាគរយ ប៉ុណ្ណោះ ដែលបានទៅពិនិត្យ

ផ្ទៃពោះចាប់ពី ៤ ដង ឡើងទៅ។ ឆ្មបជំនាញមានវត្តមាននៅពេលសម្រាលកូនចំនួន ៧១ ភាគរយ ហើយមានស្ត្រី ៥៤ ភាគរយ បានសម្រាលកូននៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យ។ គុណភាពនៃការអប់រំអំពីការថែទាំផ្ទៃពោះនិងការសម្រាលកូននៅមន្ទីរពេទ្យគួរត្រូវបានកែលម្អថែមទៀត។

ការចុះសំបុត្រកំណើតបានទាន់ពេលវេលា ត្រូវបានចាត់ទុកថាជាមធ្យោបាយដ៏សំខាន់មួយសម្រាប់ការពារសិទ្ធិទទួលបានអត្តសញ្ញាណរបស់កុមារ និងធានាឱ្យមានការសម្រេចនូវសិទ្ធិជាមូលដ្ឋានរបស់កុមារ។ ការចុះសំបុត្រកំណើត ក៏មានសារៈសំខាន់សម្រាប់កិច្ចខិតខំប្រឹងប្រែងផ្តល់ការការពារនានាដូចជាៈ (១)ទប់ស្កាត់មិនឱ្យមានពលកម្មកុមារ តាមរយៈការពង្រឹងច្បាប់ស្តីពី អាយុអប្បបរមាសម្រាប់ចូលធ្វើការងារ (២)ក្នុងការអនុវត្តជាក់ស្តែង ធានាថាកុមារដែលមានទំនាស់ជាមួយច្បាប់នឹងមិនត្រូវបានទទួលការប្រតិបត្តិតាមផ្លូវច្បាប់ដូចមនុស្សពេញវ័យ (៣)ការពារកុមារមិនឱ្យចូលបម្រើក្នុងយោធា ឬបំពេញកាតព្វកិច្ចយោធា នៅពេលដែលពួកគេមិនទាន់គ្រប់អាយុ (៤) ហាមឃាត់មិនឱ្យមានអាពាហ៍ពិពាហ៍កុមារ និង(៥)កាត់បន្ថយការជួញដូរកុមារ និងធ្វើការវាយតម្លៃលើកុមារដែលត្រូវបានបញ្ជូនឱ្យវិលត្រឡប់ទៅកាន់ប្រទេសដើមនិងជួបជុំជាមួយគ្រួសារវិញ។ ទិន្នន័យអំពីកំណើតមានសារៈសំខាន់សម្រាប់ឱ្យរាជរដ្ឋាភិបាលរៀបចំផែនការសេវាកម្មសម្រាប់ប្រជាពលរដ្ឋ កំណត់អាទិភាព រៀបចំយុទ្ធសាស្ត្រជាតិសំខាន់ៗ និងធ្វើសេចក្តីសម្រេចចិត្តអំពីការវិភាជន៍ធនធាន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្នុងឆ្នាំ២០១០ កុមារអាយុក្រោម ៥ ឆ្នាំ ចំនួន ៦២ ភាគរយ បានចុះបញ្ជីកំណើត ដែលទាបជាងតួលេខក្នុងឆ្នាំ២០០៥ ដែលមាន ៦៥ ភាគរយ។ កុមារនៅតំបន់ជនបទ ៦០ ភាគរយ បានចុះសំបុត្រកំណើតបើធៀបជាមួយនឹង ៧៤ ភាគរយ នៃកុមារនៅតំបន់ប្រជុំជន។ កុមារមកពីគ្រួសារក្រីក្របំផុត ៤៨ ភាគរយ បានចុះសំបុត្រកំណើតធៀបជាមួយនឹង ៧៨ ភាគរយ នៃកុមារមកពីគ្រួសារដែលមានជីវភាពធូរធារបំផុត។

បច្ចុប្បន្ននេះ អន្តរាគមន៍សម្រាប់កុមារតូចចាប់ពីពេលសម្រាលរហូតដល់អាយុ ៣ ឆ្នាំ នៅមានកម្រិតទាប ជាពិសេសកុមារងាយរងគ្រោះ កុមារដែលកំពុងជួបប្រទះ ឬ ប្រឈមមុខខ្ពស់ទៅនឹងបញ្ហានានាដូចជា ការលូតលាស់យឺតយ៉ាវ កង្វះអាហារូបត្ថម្ភ ពិការភាព ឬ មានឥរិយាបថខុសប្រក្រតី។ លើសពីនេះកុមារដែលកើតមកមិនគ្រប់ទម្ងន់ ឬ កុមារពិការ ជារឿយៗមិនត្រូវបានគេឱ្យកំណត់ដឹងឡើយរហូតដល់ពេលដែលពួកគេចូលរៀននៅសាលាបឋមសិក្សា។

ការផ្តល់ថ្នាំបង្ការ មានការកើនឡើងច្រើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារតែប្រសិទ្ធភាពនៃយុទ្ធនាការទូទាំងប្រទេស។ ការអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជាឆ្នាំ២០១០ បានបង្ហាញថា កុមារ ៩៤ ភាគរយ បានទទួលថ្នាំបង្ការជំងឺរបេង ៨៣,៨ ភាគរយ បានទទួលថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើង ៧៧ ភាគរយ បានទទួលថ្នាំបង្ការជំងឺកញ្ជ្រឹល ៨៣,៦ ភាគរយ បានទទួល

ថ្នាំបង្ការជំងឺខាន់ស្លាក់ ក្អកមាន់ និងតេតាណូស ៧៣ ភាគរយ បានទទួលថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ B និង ៧៣,៦ ភាគរយ បានទទួលថ្នាំបង្ការខាងលើទាំងអស់។

ករណីមរណភាពកុមារអាយុក្រោម ៥ ឆ្នាំ នៅមានកម្រិតខ្ពស់។ កុមារ ៤៨ ភាគរយ ត្រូវបានយកទៅជួបអ្នកផ្តល់សេវាសុខភាពនៅពេលសង្ស័យថាមានករណីជំងឺរលាកសួត។ ជំងឺផ្លូវដង្ហើមនានាគឺជាជំងឺដែលកើតមានឡើងមិនចេះចប់ចំពោះកុមារតូចៗក្នុងក្រុមអាយុនេះ។ កុមារ ៥០ ភាគរយទទួលបានទឹកអូរ៉ាលីតសម្រាប់ករណីជំងឺរាករូស (មានកុមារជាច្រើននាក់ទៀតដែលមិនបានទទួលការព្យាបាល)។ តាមរបាយការណ៍សុខាភិបាលសាធារណៈមានកុមារចំនួន ០,៣៦ ភាគរយ ស្លាប់ដោយសារជំងឺគ្រុនចាញ់ (ក្រសួងសុខាភិបាល ២០០៤)។ ភាគរយប្រជាជនមានហានិភ័យខ្ពស់ដែលមិនគេងក្នុងមុងជ្រលក់ថ្នាំមាន ៦៤ ភាគរយ (ក្រសួងសុខាភិបាល ២០០៧) ។ កុមារដែលឆ្លងឬទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជំងឺអេដស៍កំពុងមានការកើនឡើង ហើយអត្រាបង្ការមានកម្រិតទាប។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ អនុវិស័យអប់រំកុមារតូចនៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់តាមរយៈកម្មវិធីអប់រំកុមារតូចទាំង ៤ រូបភាពពោលគឺ (i)សាលាមត្តេយ្យសាធារណៈ (ii)សាលាមត្តេយ្យសហគមន៍ (iii)កម្មវិធីអប់រំកុមារតូចតាមផ្ទះ និង(iv)សាលាមត្តេយ្យឯកជន។ អត្រាចូលរៀនរបស់កុមារអាយុពី ៣ ដល់ ៥ ឆ្នាំ មានការកើនឡើងពី ១៣,៦ ភាគរយ នៅក្នុងឆ្នាំសិក្សា២០០៥-២០០៦ ដល់ ៣២,៧ ភាគរយ នៅក្នុងឆ្នាំសិក្សា២០១២-២០១៣ និងពី ២៧,៣ ភាគរយ ដល់ ៥៦,៥ ភាគរយ សម្រាប់កុមារអាយុ ៥ ឆ្នាំ (របាយការណ៍សន្និបាតអប់រំក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៣)។ កម្មវិធីសិក្សា ម៉ូឌុលបណ្តុះបណ្តាលនិងវិក្រឹតការ និងឯកសារបង្រៀននានា ត្រូវបានរៀបចំឡើងដើម្បីប្រើប្រាស់តាមរូបភាពអប់រំផ្សេងៗគ្នា។ កម្មវិធីអប់រំពីរភាសានិងកម្មវិធីអប់រំបញ្ចូលគ្នានៅតាមសាលាមត្តេយ្យ ត្រូវបានផ្តួចផ្តើមបង្កើតឡើងនៅក្នុងឆ្នាំ ២០១១ ដើម្បីពង្រីកការអប់រំកុមារតូច ឱ្យបានដល់កុមារមកពីក្រុមជនជាតិដើមភាគតិច និងកុមារពិការដែលខកខានមិនបានទទួលឱកាសរៀនសូត្រនៅវ័យកុមារតូច។ បើទោះបីជាមានវឌ្ឍនភាពគួរកត់សម្គាល់ទាំងនេះក៏ដោយ ក៏បញ្ហាពាក់ព័ន្ធជាមួយនឹងការគ្របដណ្តប់មិនបានទូលំទូលាយដល់តំបន់ជនបទភាគច្រើននៅឡើយ ហើយការរៀបចំស្តង់ដាគុណភាពនៃការរៀនសូត្រនៅតាមកម្មវិធីនានា ក៏ដូចជាការលើកទឹកចិត្តនិងការរក្សាគ្រូមត្តេយ្យសហគមន៍នៅមានកម្រិតទាប។

ការអប់រំថ្នាក់មូលដ្ឋានក្នុងប្រព័ន្ធ គឺជាមុខងារមួយនៃការអភិវឌ្ឍកុមារតូចនិងការរៀបចំផែនការដើម្បីពង្រីកធនធានថវិកាអប់រំឱ្យដល់កម្រិតអតិបរមា។ អត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សាបានកើនឡើងដល់ ៩៨,២ ភាគរយ នៅក្នុងឆ្នាំសិក្សា២០១៣-២០១៤ (ក្រសួងអប់រំយុវជន និងកីឡាឆ្នាំ២០១៤)។ អត្រាបញ្ចប់ការសិក្សាកម្រិតបឋមសិក្សាឆ្នាំសិក្សាឆ្នាំ២០១២-២០១៣ មាន ៨៨,៩៤ ភាគរយ ។ អត្រាបោះបង់ការសិក្សានៅបឋមសិក្សា ១០,៥ ភាគរយ។ ការរៀន

ត្រួតថ្នាក់មានអត្រាជាមធ្យម ៩,៨ ភាគរយ ហើយមានកម្រិតខ្ពស់នៅតំបន់ជនបទ (ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១៤)។ ប្រសិទ្ធភាពផ្ទៃក្នុងរបស់ប្រព័ន្ធអប់រំមានកម្រិតទាប នាំឱ្យមានការខាតបង់ខ្ពស់របស់សង្គម។ តាមការស្រាវជ្រាវជាច្រើននៅក្នុងពិភពលោកបង្ហាញថា ការវិនិយោគលើការគាំពារនិងការអភិវឌ្ឍកុមារតូច ពិតជាអាចកាត់បន្ថយបានច្រើនលើបញ្ហាបាត់ប្រសិទ្ធភាពផ្ទៃក្នុងរបស់ប្រព័ន្ធអប់រំ និងអាចបង្កើនលទ្ធផលសិក្សារបស់សិស្ស ហើយពង្រីកបានចំនួនកម្លាំងពលកម្មដែលចេះអក្សរ។ លើសពីនេះមានការបង្ហាញផងដែរថាបើមានការសន្សំសំចៃជាច្រើនដែលបានពីការបង្កើនប្រសិទ្ធភាពផ្ទៃក្នុងនៃការអប់រំនៅបឋមសិក្សា គឺអាចយកមកប៉ះប៉ូវរងចំណាយសម្រាប់សេវាគាំពារនិងអភិវឌ្ឍកុមារតូចទាំងអស់បាន (Jaramillo and Mingat 2007)។

ការប៉ាន់ប្រមាណថា កុមារកម្ពុជាអាយុពី ០ ដល់ ១៧ ឆ្នាំ ចំនួន ៦០០.០០០ នាក់ជាកុមារកំព្រា (យូនីសេហ្វឆ្នាំ២០០៧) ហើយមានកុមារកំព្រាដល់វ័យចូលរៀនត្រឹមតែ ៨៣ ភាគរយប៉ុណ្ណោះដែលត្រូវបានរាយការណ៍ថា បានចូលរៀននៅតាមសាលារៀននានា។ ដោយសារតែកង្វះសេវាសុខុមាលភាពសង្គម ប្រជាពលរដ្ឋក្រីក្រជាច្រើនគ្រួសារកំពុងលះបង់ចោលគុណតម្លៃប្រពៃណី ដែលផ្តល់អាទិភាពដល់ការថែទាំតាមគ្រួសារនិងសហគមន៍ ហើយបែរជាទៅពឹងផ្អែកលើការថែទាំតាមមណ្ឌលវិញ ដែលនេះជានិន្នាការមួយរួមចំណែកដល់ការកើនឡើងយ៉ាងឆាប់រហ័សនៃការផ្តល់ការថែទាំតាមមណ្ឌល ដែលពុំទាន់មានការគ្រប់គ្រងបានត្រឹមត្រូវនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងឆ្នាំ ២០១៣ មានកុមារជាង ១១.០០០ នាក់ កំពុងរស់នៅតាមមណ្ឌល ដើម្បីទទួលបានការថែទាំ។ គេប៉ាន់ប្រមាណថា ៧២ ភាគរយ នៃកុមារទាំងនោះ យ៉ាងហោចណាស់មានម្តាយ ឬឪពុកដែលនៅរស់នៅឡើយ។ ការស្រាវជ្រាវអន្តរជាតិបានបង្ហាញឱ្យឃើញថា មជ្ឈមណ្ឌលថែទាំកុមារមួយចំនួនពុំទាន់មានលក្ខណៈសមស្របនៅឡើយ ដែលជាហេតុនាំឱ្យការអភិវឌ្ឍរបស់ពួកគេមានភាពយឺតយ៉ាវ មានអារម្មណ៍មិននឹងនរ និងមានសមត្ថភាពអភិវឌ្ឍបំណិនសង្គមដែលចាំបាច់មិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ។ ជាការចាំបាច់ត្រូវតែមានការគាំទ្រដែលមានលក្ខណៈជាយុទ្ធសាស្ត្របន្ថែមទៀត ដើម្បីជំរុញការកែលម្អមណ្ឌលថែទាំកុមារឱ្យមានលក្ខណៈប្រសើរឡើង និងបង្ការមិនឱ្យមានការរស់នៅបែកពីមាតាបិតារបស់ពួកគេដោយមិនចាំបាច់ និងជំរុញឱ្យមានការធ្វើសមាហរណកម្មចូលទៅក្នុងគ្រួសារពួកគេវិញ ចំពោះអ្នកដែលរស់នៅបែកពីគ្រួសារកន្លងមក។

អំពើហិង្សាលើកុមារជាបញ្ហាមួយនៅក្នុងប្រទេសកម្ពុជា ដែលអាចនាំឱ្យមានគ្រោះថ្នាក់ផ្ទាល់ ឬ បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព ការរស់រាន ការអភិវឌ្ឍ ឬសេចក្តីថ្លៃថ្នូររបស់កុមារ។ គិតត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ កុមារចំនួន ៣១ នាក់ ក្នុងនោះស្រី ១៨ នាក់ ត្រូវបានឃុំខ្លួនជាមួយនិងម្តាយរបស់ពួកគេនៅក្នុងពន្ធនាគារ ដែលភាគច្រើនមានអាយុក្រោម ៣ ឆ្នាំ (តាមតួលេខរបស់អគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ)។ តាមច្បាប់ស្តីពីពន្ធនាគារឆ្នាំ ២០១១

កុមារដែលរស់នៅជាមួយនឹងម្តាយដែលជាប់ក្នុងមន្ទីរឃុំឃាំងត្រូវបានដកចេញពីមន្ទីរឃុំឃាំង នៅពេលដែលពួកគេមានអាយុ ៣ ឆ្នាំ។

ប្រទេសកម្ពុជាជាប្រទេសបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងផ្តល់សច្ចាប័នលើពិធីសារបន្ថែមពីរ ស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ពេស្យាកម្មកុមារ និងរូបភាពអាសអាភាសកុមារនៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០០២។

ទោះបីជាប្រទេសកម្ពុជាបានសម្រេចនូវវឌ្ឍនភាពធំៗជាច្រើន ក្រោយពេលមានការបំផ្លិចបំផ្លាញដោយសារសង្គ្រាម និងសម័យកាលរីករវបន្តបន្ទាប់ ចាប់ពីឆ្នាំ១៩៧០ ដល់ ១៩៩៣ ក៏ដោយក៏ស្ថានភាពរបស់ទារកនិងកុមារតូចនៅតែជាក្តីបារម្ភដ៏ធំមួយ។ ប្រសិនបើស្ថានភាពរបស់កុមារតូចមិនមានការរីកចម្រើនឱ្យបានឆាប់រហ័សនោះទេ គេក៏នឹងមិនអាចសម្រេចឱ្យបាននូវសិទ្ធិកុមារបានដែរ កុមារជាច្រើននាក់នឹងនៅតែទទួលរងការឈឺចាប់ ហើយប្រទេសនឹងខ្វះធនធានមនុស្សដែលទទួលបានការអប់រំ និងការបណ្តុះបណ្តាលបានល្អ ដែលជាមូលដ្ឋានចាំបាច់ដើម្បីសម្រេចនូវគោលដៅអភិវឌ្ឍន៍ជាតិ។

## ១.៣ បញ្ហាអាទិភាព

ផ្អែកតាមការវិភាគស្ថានភាពខាងលើ ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចផ្តោតការយកចិត្តទុកដាក់ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការសម្រាលកូនជំនាញចិញ្ចឹមបីបាច់អប់រំកូនរបស់មាតាបិតា និងការអភិវឌ្ឍកុមារ សំដៅសម្រេចឱ្យបាននូវសក្តានុពលពេញលេញរបស់កុមារគ្រប់រូបនៅក្នុងប្រទេសកម្ពុជា និងកាត់បន្ថយវិសមភាពសង្គមដែលកើតឡើងដោយសារតែសេវាសុខភាព អាហារូបត្ថម្ភមានភាពមិនគ្រប់គ្រាន់ និងលទ្ធផលនៃការសិក្សានៅមានកម្រិតទាប។

ផែនការសកម្មភាពនេះនឹងដាក់ចេញនូវអន្តរាគមន៍អប់រំកុមារតូច សេវាអប់រំបញ្ចូលគ្នាសម្រាប់កុមារងាយរងគ្រោះ កុមារជនជាតិដើមភាគតិច ដែលកំពុងទទួលរង ឬ ប្រឈមមុខខ្ពស់ទៅនឹងការលូតលាស់យឺតយ៉ាវ កង្វះអាហារូបត្ថម្ភ និងពិការភាព។

ការវិនិយោគលើការគាំពារនិងអភិវឌ្ឍន៍កុមារតូច នាំឱ្យមានការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ និងការកាត់បន្ថយតម្រូវការនៃការផ្តល់សេវាដែលអស់ចំណាយច្រើន ដូចជាសេវាពាក់ព័ន្ធជាមួយនឹងយុត្តិធម៌ព្រហ្មទណ្ឌ ពន្ធនាគារ និងសុខុមាលភាពសង្គមជាដើម។

ការអនុវត្តផែនការសកម្មភាពជាតិនេះនឹងជំរុញឱ្យមានការចុះឈ្មោះចូលរៀនទាន់ពេលវេលាពោលគឺនៅអាយុ ៦ ឆ្នាំ។ ការលើកកម្ពស់លទ្ធផលសិក្សា និងការបង្កើនប្រសិទ្ធភាពផ្ទៃក្នុងរបស់ប្រព័ន្ធអប់រំ។

ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចជាមូលដ្ឋានសម្រាប់ចូលរួមចំណែកដល់ការបង្កើនផលិតភាពសេដ្ឋកិច្ចគ្រួសារនិងសង្គម និងសមត្ថភាពប្រកួតប្រជែងរបស់ជាតិផង។ បញ្ហាអាទិភាពរួមមាន ៖

- **ការពង្រីកនិងបង្កើនគុណភាពសេវាគាំពារនិងអភិវឌ្ឍកុមារតូច**
    - ការអប់រំស្ត្រីមានផ្ទៃពោះនិងមាតាបិតា ឬ អ្នកថែទាំកុមារ៖ ការប្រើប្រាស់មធ្យោបាយពន្យារកំណើត ការប្រើប្រាស់សេវាពិគ្រោះយោបល់នៅមណ្ឌលសុខភាព និងការសម្រាលកូននៅមណ្ឌលសុខភាពមន្ទីរពេទ្យ ឬ គ្រឹះស្ថានសុខាភិបាល
    - ការលើកកម្ពស់អាហារូបត្ថម្ភនិងកាយសម្បទាកុមារ៖ ការផ្តល់មីក្រូសារជាតិ (វីតាមីន និងរ៉ែខនិជ) ការផ្តល់ថ្នាំបង្ការ ការប្រើប្រាស់បង្គន់អនាម័យនិងទឹកស្អាត ការបង្កើនកម្រិតអាហារូបត្ថម្ភដល់កុមារ និងការប្រើប្រាស់សេវាសុខាភិបាល
    - ការផ្តល់សំបុត្រកំណើត៖ ការចុះបញ្ជីកំណើតកុមារឱ្យបានគ្រប់គ្នា
    - ការទប់ស្កាត់អំពើហិង្សានិងពលកម្មកុមារ៖ ការទប់ស្កាត់រាល់ទម្រង់នៃអំពើហិង្សាលើកុមារ ការទប់ស្កាត់មិនឱ្យមានពលកម្មកុមារ ការលុបបំបាត់ការជួញដូរកុមារ ការផ្តល់ការការពារផ្លូវច្បាប់ដល់កុមារពីការបំបែកពីគ្រួសារដោយមិនចាំបាច់

- ការអប់រំកុមារតូច៖ ការបង្កើនការចូលរៀននិងការគាំពារដល់កុមារអាយុពី ០ ដល់ក្រោម ៦ ឆ្នាំ ជាពិសេសកុមារមកពីគ្រួសារក្រីក្រ ជនជាតិដើមភាគតិច កុមារតូចរងគ្រោះ កុមារតូចងាយរងគ្រោះ និងកុមារមានពិការភាព ព្រមទាំងផ្តល់អាទិភាពដល់សាលាមត្តេយ្យសិក្សាសហគមន៍ និងអប់រំកុមារតូចតាមផ្ទះនិងខ្នងផ្ទះ។

- **ក្របខណ្ឌការងារ យន្តការការងារ និងការសម្របសម្រួលក្នុងការគាំពារនិងអភិវឌ្ឍន៍កុមារតូច**
    - ការបង្កើតក្របខណ្ឌគតិយុត្តៈ ការធ្វើទំនើបកម្មច្បាប់និងគោលនយោបាយ ការផ្ទេរមុខងារឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្សនិងពលកម្មកុមារ ការលើកកម្ពស់យេនឌ័រ ការជំរុញការអនុវត្តយន្តការប្រឆាំងអំពើពុករលួយ
    - ការបង្កើតយន្តការសម្របសម្រួលពហុវិស័យនៅគ្រប់កម្រិត៖ គណៈកម្មការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យនិងអនុគណៈកម្មការពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

- **ការកៀរគរធនធានសម្រាប់គាំទ្រដល់សកម្មភាពគាំពារនិងអភិវឌ្ឍកុមារតូច**
    - ការបង្កើនភាពជាដៃគូក្នុងការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច៖ សមាហរណកម្មផែនការជាមួយគ្នារវាងស្ថាប័នសាធារណៈ ស្ថាប័នឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍក្នុងការគាំពារនិងអភិវឌ្ឍកុមារតូច
    - ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគថ្នាក់ឃុំសង្កាត់៖ ជំរុញឱ្យឃុំសង្កាត់ដាក់សកម្មភាពគាំពារ និងអភិវឌ្ឍកុមារតូចទៅក្នុងផែនការអភិវឌ្ឍរបស់ខ្លួនហើយធ្វើការបង្កើនចំណាយលើការគាំពារ និងអភិវឌ្ឍន៍កុមារតូចទៅក្នុងថវិកាកម្មវិធីវិនិយោគឃុំសង្កាត់និងប្រភពផ្សេងទៀត។

- **ក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃរួមគ្នាអំពីសកម្មភាពគាំពារនិងអភិវឌ្ឍកុមារតូច**
    - ការពិនិត្យតាមដាននិងវាយតម្លៃ៖ ការកំណត់តួនាទី ភារកិច្ច និងសម្របសម្រួលការកំណត់សូចនាករ ការប្រមូលទិន្នន័យ ការវិភាគ និងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនិងផលប៉ះពាល់នៃកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច
    - ការពិនិត្យមើលឡើងវិញលើគោលនយោបាយ៖ ការសិក្សាពីជម្រើសគោលនយោបាយនិងផលប៉ះពាល់នៃការអនុវត្តគោលនយោបាយ។



# ២. យុទ្ធសាស្ត្រ

## ២. យុទ្ធសាស្ត្រ

1. រៀបចំក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការ ដើម្បីគាំទ្រនិងអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាពដោយកំណត់ឱ្យមានកិច្ចសហការ និងភារកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ។
2. កែលម្អយន្តការតាមដានវាយតម្លៃ ដែលមានស្រាប់ឬបង្កើតថ្មី ដោយមានការចូលរួមពីក្រសួង ស្ថាប័ន សហគមន៍ ដៃគូអភិវឌ្ឍនានា និងកែលម្អគណៈកម្មការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយបែងចែកភារកិច្ចនិងការទទួលខុសត្រូវឱ្យបានច្បាស់លាស់។
3. កសាងសមត្ថភាព (បណ្តុះបណ្តាលមុន និងកំពុងបម្រើការងារ) អ្នកអនុវត្តកម្មវិធី មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាកុមារលើខ្លឹមសារ និងវិធីថែទាំឱ្យស្របតាមកម្មវិធីសិក្សានិងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។
4. បង្កើតយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់វិញ្ញាបនបត្រឬលិខិតទទួលស្គាល់ដល់អ្នកអនុវត្តកម្មវិធីទៅតាមសេវាថែទាំជាក់ស្តែង។
5. បង្កើនសេវានិងការអប់រំស្តីអំពីការថែទាំសុខភាពនិងអាហារូបត្ថម្ភដល់ស្ត្រីទាំងអស់ ដែលមានផ្ទៃពោះ។
6. បង្កើនសេវាថែទាំ ព្យាបាល សុខភាព ជំងឺ ដល់កុមារតូចចាប់ពីពេលកើតដល់អាយុ ៣ ឆ្នាំ ដោយពិនិត្យសុខភាពជាប្រចាំ ផ្តល់ថ្នាំបង្ការទាន់ពេល និងពេញលេញ ហើយតាមដាន ការផ្តល់សេវា អាហារូបត្ថម្ភ ចំពោះកុមារដែលខ្វះអាហារូបត្ថម្ភ មានជំងឺរុំារ៉ៃ លូតលាស់យឺតពិការ។
7. ពង្រីកការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចរួមមាន សេវារដ្ឋ សេវាសហគមន៍ សេវាឯកជន តាមផ្ទះ និងតាមខ្ទងផ្ទះ ជាពិសេសការហាត់រៀនពីដំបូងចំពោះកុមារតូច។
8. ធានាឱ្យគ្រប់គ្រួសារទទួលបានព័ត៌មាន និងសេវាដូចជា ទឹកស្អាតនិងអនាម័យ សុខភាព អាហារូបត្ថម្ភ ការបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់អាហារបន្ថែម ការទទួលថ្នាំបង្ការជីវជាតិអា ជាតិដែក និងអំបិលអ៊ីយ៉ូដ ការរៀនពីដំបូង ការចុះបញ្ជីកំណើត ការទប់ស្កាត់ជំងឺឆ្លងគ្រប់ប្រភេទមានជាអាទិ៍ មេរោគអេដស៍និងជំងឺអេដស៍ ជំងឺគ្រុនចាញ់ ការការពារគ្រួសារពីអំពើហិង្សា និងការរងគ្រោះដោយប្រការផ្សេងៗ។
9. បង្កើតឱ្យមានយន្តការផ្សព្វផ្សាយព័ត៌មានអំពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចសម្រាប់ទាក់ទាញការគាំទ្រសេវាទាំងនោះ។

**យុទ្ធសាស្ត្រទី ១ ៖ រៀបចំក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការ ដើម្បីគាំទ្រ និងអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាព ដោយកំណត់ឱ្យមានកិច្ចសហការ និងភារកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ**

- **គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច (គ.ជ.គ.ក.)៖** មានសមាសភាពពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងពាក់ព័ន្ធចំនួន១០ និងទីស្តីការគណៈរដ្ឋមន្ត្រី។ គណៈកម្មាធិការនេះនឹងធានានូវនិរន្តរភាពនៃប្រព័ន្ធការងារគាំពារនិងអភិវឌ្ឍកុមារតូច តាមរយៈការផ្តល់ការណែនាំនិងបង្កលក្ខណៈងាយស្រួលដល់ការអនុវត្តគោលនយោបាយជាតិ ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច និងភារកិច្ចដូចខាងក្រោម៖

1. ជំរុញក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានា ដើម្បីអនុវត្តតួនាទីភារកិច្ចដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចឱ្យមានប្រសិទ្ធភាព
2. ជំរុញនិងសម្របសម្រួលដល់គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ រៀបចំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ ដើម្បីធានាបាននូវការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចឱ្យមានប្រសិទ្ធភាព
3. ជំរុញនិងសម្របសម្រួលការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិ
4. សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់
5. អនុម័តនិងផ្សព្វផ្សាយគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចដល់ក្រសួង ស្ថាប័ន អង្គការជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
6. រៀបចំក្របខណ្ឌច្បាប់សម្រាប់អនុវត្តកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច
7. បង្កើតយន្តការស្រាវជ្រាវដើម្បីកំណត់អត្តសញ្ញាណ ស្វែងរក និងពិនិត្យមើលទាន់ពេលវេលាសម្រាប់កុមារតូចដែលមានតម្រូវការពិសេស និងពិការភាព
8. រៀបចំយន្តការគាំទ្រសេវារដ្ឋ សេវាសហគមន៍ សេវាឯកជន តាមផ្ទះ និងតាមខ្នងផ្ទះក្នុងការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចដោយយកចិត្តទុកដាក់ចំពោះកុមារដែលរស់នៅក្នុងតំបន់ជួបការលំបាក កុមារជនជាតិដើមភាគតិច និងកុមារបាត់បង់ឱកាស
9. ពិនិត្យនិងកែលម្អគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច
10. កៀរគរធនធានសម្រាប់គាំទ្រការអនុវត្តការគាំពារនិងអភិវឌ្ឍន៍កុមារតូច
11. ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តគ្រប់កម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច

12. ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការគាំពារនិងអភិវឌ្ឍន៍កុមារតូចដើម្បីដាក់ជូនរាជរដ្ឋាភិបាល
13. ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

- **អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច៖** អគ្គលេខាធិការដ្ឋានមានភារកិច្ច៖

1. គ្រប់គ្រងកិច្ចការរដ្ឋបាលនិងបច្ចេកទេសដែលធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់ គ.ជ.គ.ក.
2. ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទទួលបានការយល់ព្រមពី គ.ជ.គ.ក. ដល់គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ
3. គ្រប់គ្រងហិរញ្ញវត្ថុរបស់ គ.ជ.គ.ក.
4. ពិនិត្យតាមដាន វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច
5. លើកសំណើសុំពិនិត្យនិងកែលម្អគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចជូន គ.ជ.គ.ក.
6. សហការជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ
7. ធ្វើរបាយការណ៍ជូន គ.ជ.គ.ក.
8. ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងៗទៀតដែល គ.ជ.គ.ក. ប្រគល់ជូន។

**អង្គការលេខនៃអគ្គលេខាធិការដ្ឋាន គ.ជ.គ.ក.**



**គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ៖** មានសមាសភាពជាមន្ត្រីបច្ចេកទេសនិងអ្នកពាក់ព័ន្ធដទៃទៀតតាមវិស័យរៀងៗខ្លួន។ គណៈកម្មាធិការនេះនឹងជួយដល់ គ.ជ.គ.ក. ដើម្បីធានាឱ្យការអនុវត្តសកម្មភាពនានាបានទាន់ពេលវេលាទាក់ទងនឹងតួនាទីនិងភារកិច្ច ដើម្បីគាំពារនិងអភិវឌ្ឍកុមារតូចឱ្យមានប្រសិទ្ធភាពរៀងៗខ្លួន។ គណៈកម្មាធិការនេះអាចបង្កើតអនុគណៈកម្មាធិការមួយចំនួនតាមការចាំបាច់។

- ប្រព័ន្ធការងារគាំពារនិងអភិវឌ្ឍកុមារតូចតាមបែបវិមជ្ឈការ ៖ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូចត្រូវសហការជិតស្និទ្ធជាមួយ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារនៅរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌនិងគណៈកម្មាធិការកិច្ចការនារីនិងកុមារឃុំ-សង្កាត់ ដើម្បីធានាថាការរៀបចំផែនការប្រចាំឆ្នាំការសម្របសម្រួលការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍ប្រចាំត្រីមាសអំពីសកម្មភាពគាំពារនិងអភិវឌ្ឍកុមារតូច។

## យុទ្ធសាស្ត្រទី ២ ៖ កែលម្អយន្តការតាមដានវាយតម្លៃ ដែលមានស្រាប់ ឬ បង្កើតថ្មីដោយមានការចូលរួមពីក្រសួង ស្ថាប័ន សហគមន៍ ដៃគូអភិវឌ្ឍនានា និងកែលម្អគណៈកម្មការសម្របសម្រួល បច្ចេកទេសថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយបែងចែកភារកិច្ចនិងការទទួលខុសត្រូវឱ្យបានច្បាស់លាស់

- ការបង្កើតមូលដ្ឋានទិន្នន័យ និងយន្តការរាយការណ៍ទូទាំងប្រទេសមួយ សម្រាប់ធ្វើការពិនិត្យតាមដានវាយតម្លៃ និងសម្របសម្រួលការងារគាំពារ និងអភិវឌ្ឍកុមារតូចដោយប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់ នៅតាមក្រសួងនិងស្ថាប័នពាក់ព័ន្ធ។ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូចទទួលខុសត្រូវលើការសម្របសម្រួលការប្រមូលទិន្នន័យដែលបានពីក្រសួងស្ថាប័នពាក់ព័ន្ធតាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ និងបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ វាយតម្លៃ និងផ្សព្វផ្សាយពីវឌ្ឍនភាពរបស់ការងារគាំពារនិងអភិវឌ្ឍកុមារតូច។
    - ដើម្បីរៀបចំយន្តការពិនិត្យតាមដាននិងវាយតម្លៃបានចាំបាច់ត្រូវមានការសិក្សាវិភាគដំបូងមួយ ដើម្បីកំណត់និងរៀបរាប់ពីមុខងារពិនិត្យតាមដាននិងវាយតម្លៃសេវាលិខិតឧបករណ៍ និងធនធានដែលមានស្រាប់ ពាក់ព័ន្ធនឹងសេវាគាំពារនិងអភិវឌ្ឍកុមារតូចដូចជា ៖ សុខភាព អាហារូបត្ថម្ភ ការអប់រំ កិច្ចគាំពារសង្គម និងអនាម័យ តាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ ប្រព័ន្ធព័ត៌មានសុខាភិបាល មូលដ្ឋានទិន្នន័យឃុំសង្កាត់ មូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ការអង្កេតគ្រួសារជាប្រចាំការអង្កេតសង្គម សេដ្ឋកិច្ចកម្ពុជា ការអង្កេតប្រជាសាស្ត្រនិងសុខភាព

- ការពិនិត្យតាមដាន វាយតម្លៃនិងរបាយការណ៍ត្រូវមាននៅគ្រប់កម្រិតទាំងអស់ ចាប់ពីថ្នាក់ឃុំ សង្កាត់ ដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត និងថ្នាក់ជាតិ ជាពិសេសនៅថ្នាក់ឃុំ សង្កាត់ ដោយមានការរៀបចំទម្រង់របាយការណ៍សម្រាប់កម្រិតនីមួយៗ។ សៀវភៅណែនាំស្តីពីការពិនិត្យតាមដាននិងវាយតម្លៃ ដែលរួមមានគ្រប់ឧបករណ៍ និងទម្រង់ជាមូលដ្ឋានទាំងអស់ នឹងត្រូវរៀបចំឡើង ដើម្បីធ្វើការសាកល្បងនៅមូលដ្ឋាន កែសម្រួល ហើយដាក់ឱ្យអនុវត្តនៅតាមឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌនីមួយៗ
  - របាយការណ៍ទាំងនេះនឹងត្រូវប្រមូលចងក្រង ដោយអគ្គលេខាធិការដ្ឋានគាំពារនិងអភិវឌ្ឍកុមារតូច ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំសម្រាប់ដាក់ជូនគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ដែលមានដាក់បញ្ចូលនូវសេចក្តីសង្ខេបរួមនិងអនុសាសន៍ សម្រាប់អនាគតដែលនឹងត្រូវផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធឱ្យបានទូលំទូលាយ
  - មូលដ្ឋានទិន្នន័យនឹងត្រូវពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នកម្មរៀងរាល់៥ឆ្នាំ។
- សេវាគាំពារនិងអភិវឌ្ឍកុមារតូចដែលអនុវត្តដោយដៃគូអភិវឌ្ឍ អង្គការជាតិ និងសង្គមស៊ីវិលនឹងត្រូវបញ្ចូលក្នុងគោលដៅសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីឱ្យគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូចអាចកំណត់បទពិសោធល្អៗ សម្រាប់បញ្ជ្រាប និងផ្សព្វផ្សាយទូទាំងប្រទេស។

## **យុទ្ធសាស្ត្រទី ៣** ៖ កសាងសមត្ថភាព (ការបណ្តុះបណ្តាលមុនពេល និងកំពុងបម្រើការងារ) អ្នក អនុវត្តកម្មវិធី មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាកុមារលើខ្លឹមសារ និងវិធីថែទាំឱ្យស្របតាមកម្មវិធីសិក្សា និងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។

- ការបណ្តុះបណ្តាលនិងវិក្រឹតការសម្រាប់អ្នកផ្តល់សេវាគាំពារ និងអភិវឌ្ឍកុមារតូច ដើម្បីពង្រីកសេវាគាំពារនិងអភិវឌ្ឍកុមារតូច និងបង្កើនគុណភាពការងាររបស់អ្នកផ្តល់សេវាផ្អែកទៅតាមក្រមសីលធម៌។
  - ការបណ្តុះបណ្តាលអ្នកគ្រប់គ្រងការផ្តល់សេវាគាំពារ និងអភិវឌ្ឍកុមារតូចរួមមានមន្ត្រីគ្រប់គ្រងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អ្នកគ្រប់គ្រងសាលាមត្តេយ្យសិក្សាឯកជន មត្តេយ្យសិក្សាសហគមន៍ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថាន និងស្ថាប័នផ្សេងៗទៀត
  - ការបណ្តុះបណ្តាលនិងវិក្រឹតការបុគ្គលិកនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអ្នកផ្តល់សេវាគាំពារ និងអភិវឌ្ឍកុមារតូចនៅថ្នាក់មូលដ្ឋានពាក់ព័ន្ធជំនាញអប់រំ សុខភាព

អាហារូបត្ថម្ភ អនាម័យ កិច្ចការពារកុមារ សង្គមកិច្ច ចិត្តសាស្ត្រ អន្តរាគមន៍កុមារតូច និងការអភិវឌ្ឍសហគមន៍ជាដើម។

- ប្រព័ន្ធបណ្តុះបណ្តាល និងវិក្រឹតការនៅថ្នាក់ជាតិនឹងត្រូវបង្កើតឡើងដើម្បីអនុវត្តនៅតាមស្ថាប័នបណ្តុះបណ្តាលដែលមានស្រាប់។ ផែនការអភិវឌ្ឍសមត្ថភាពក៏ត្រូវរៀបចំផងដែរ ដើម្បីបំពេញគម្លាតនៃការផ្តល់សេវា។
    - ការសិក្សាមួយនឹងត្រូវធ្វើឡើងដើម្បីពិនិត្យមើលវឌ្ឍនភាពកន្លងមក ស្ថានភាពបច្ចុប្បន្ននៃសេវាគាំពារ និងអភិវឌ្ឍកុមារតូច ក៏ដូចជាធ្វើការកំណត់រៀបចំបញ្ជីវិភាគ និងវាយតម្លៃលើសមត្ថភាព និងគម្លាតក្នុងការបណ្តុះបណ្តាល។ ការសិក្សានេះនឹងកំណត់ពីធនធានបណ្តុះបណ្តាលមានស្រាប់ លទ្ធភាពដែលអាចពង្រីកបន្ថែម និងការបំពេញគម្លាត
    - ការបណ្តុះបណ្តាល និងវិក្រឹតការធ្វើឡើងតាមរយៈសាកលវិទ្យាល័យជាតិ សាលាគរុកោសល្យ សាលាបច្ចេកទេស និងស្ថាប័នបណ្តុះបណ្តាលសាធារណៈ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ ដែលតែងផ្តល់ការគាំទ្រជាប្រចាំដល់ការគាំពារនិងអភិវឌ្ឍន៍កុមារតូច
    - ការបណ្តុះបណ្តាល និងវិក្រឹតការជំនាញគាំពារនិងអភិវឌ្ឍកុមារតូច ត្រូវផ្អែកទៅតាមកម្មវិធីសិក្សា ឯកសារបណ្តុះបណ្តាលនិងវិធីសាស្ត្រដែលល្អបំផុត។ អគ្គលេខាធិការដ្ឋានត្រូវសម្របសម្រួលរៀបចំសៀវភៅណែនាំអំពីការបណ្តុះបណ្តាលរួម
    - ការបណ្តុះបណ្តាល និងវិក្រឹតការមានរូបភាពជាការបណ្តុះបណ្តាលមុនពេលបំពេញការងារ ការបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតមូលដ្ឋាន ការបណ្តុះបណ្តាលរយៈពេលខ្លី ការបណ្តុះបណ្តាលនៅនឹងកន្លែងស្របតាមកម្មវិធីសិក្សាជាតិ ផ្សារភ្ជាប់នឹងកម្មវិធីសិក្សារបស់បណ្តាប្រទេសក្នុងតំបន់ព្រមទាំងទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធ។
- ការរៀបចំនីតិវិធីនិងក្រមសីលធម៌សម្រាប់អ្នកផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច ដើម្បីធានាឱ្យមានការចាត់វិធានការបន្ទាន់នៅក្នុងករណីដែលចាំបាច់ ជាពិសេសនៅពេលដែលមានការរាយការណ៍ពីករណីរំលោភបំពាននានា។

**យុទ្ធសាស្ត្រទី៤ ៖ បង្កើតយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់វិញ្ញាបនបត្រ ឬលិខិត ទទួលស្គាល់ដល់អ្នកអនុវត្តកម្មវិធីទៅតាមសេវាថែទាំជាក់ស្តែង**

- ការផ្តល់នូវសញ្ញាបត្រនិងវិញ្ញាបនបត្រដល់អ្នកបានឆ្លងកាត់ការបណ្តុះបណ្តាលនិងវិក្រឹតការតាមគ្រប់រូបភាព
  - ជំរុញកិច្ចសហប្រតិបត្តិការពីគ្រប់ភាគីពាក់ព័ន្ធ តាមរយៈការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីរួមគ្នាកំណត់ពីប្រព័ន្ធទទួលស្គាល់គុណភាពបណ្តុះបណ្តាលសេវាគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅគ្រប់រូបភាព
  - ការកំណត់ស្តង់ដារស្ថាប័នបណ្តុះបណ្តាល និងកម្មវិធីបណ្តុះបណ្តាល ដើម្បីទទួលស្គាល់គុណភាពបណ្តុះបណ្តាល
  - ការផ្តល់វិញ្ញាបនបត្រដល់អ្នកដែលបានបញ្ចប់ការបណ្តុះបណ្តាល និងវិក្រឹតការមុខជំនាញស្របតាមកម្រិតនៃការបណ្តុះបណ្តាល និងចេញដោយស្ថាប័នបណ្តុះបណ្តាលដែលបានទទួលស្គាល់
  - ការរៀបចំមូលដ្ឋានទិន្នន័យគ្រប់គ្រងអ្នកដែលបានទទួលសញ្ញាបត្រឬវិញ្ញាបនបត្រ ដើម្បីរៀបចំផែនការវិក្រឹតការ ឬ សុក្រឹតការទៀងទាត់
  - ការកំណត់លក្ខខណ្ឌ និងការផ្តល់ក្រេឌីតសម្រាប់ការបណ្តុះបណ្តាលបន្តដល់អ្នកឯកទេសផ្នែកអន្តរាគមន៍ទាន់ពេលវេលាសម្រាប់កុមារតូច អ្នកអប់រំមត្តេយ្យសិក្សា អ្នកជំនាញផ្នែកចិត្តសាស្ត្រ ភ្នាក់ងារសង្គម និងអ្នកជំនាញផ្សេងទៀត។

**យុទ្ធសាស្ត្រទី ៥ ៖ បង្កើនសេវានិងការអប់រំស្តីអំពីការថែទាំសុខភាពនិងអាហារូបត្ថម្ភដល់ស្ត្រីទាំងអស់ដែលមានផ្ទៃពោះ។**

- ការផ្សព្វផ្សាយអំពីការរៀបចំផែនការគ្រួសារ និងការប្រឹក្សាមុនពេលសម្រេចចិត្តមានផ្ទៃពោះទៅតាមការចាំបាច់
- ការលើកកម្ពស់ការអប់រំអំពីការថែទាំផ្ទៃពោះ ការពិនិត្យផ្ទៃពោះឱ្យបានទាន់ពេលវេលានិងទៀងទាត់ ដើម្បីកាត់បន្ថយបញ្ហាមរណភាពទារកនិងមាតា បញ្ហាកូនកើតមិនគ្រប់ខែ បញ្ហាកូនកើតមិនគ្រប់ទម្ងន់ និងបញ្ហាកូនមានភាពមិនប្រក្រតីនៅពេលសម្រាល
- ការយល់ដឹងពីសារៈសំខាន់នៃអាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ តាមរយៈការប្រឹក្សានិងការផ្តល់អាហារូបត្ថម្ភ ការស្តារស្ថានភាពអាហារូបត្ថម្ភ និងមីក្រូសារជាតិ (ជាតិដែក អាស៊ីដហ្វូលិក ។ល។ ទៅតាមការចាំបាច់)

- ការកែលម្អទម្លាប់និងឥរិយាបថក្នុងការសម្រាលកូននៅមន្ទីរពេទ្យ ឬ មណ្ឌលសុខភាព ធានាយ៉ាងណាឱ្យស្ត្រីមានផ្ទៃពោះមានផែនការធ្វើដំណើរទៅកាន់អ្នកផ្តល់សេវាសុខភាព ដែលទទួលស្គាល់ ឬ ទៅកាន់មន្ទីរពេទ្យ ដើម្បីសម្រាលកូនជាពិសេសជនជាតិដើមភាគតិច។

**យុទ្ធសាស្ត្រទី៦៖ បង្កើនសេវាថែទាំព្យាបាលសុខភាព ជំងឺ ដល់កុមារតូចចាប់ពីពេលកើតដល់អាយុ ៣ ឆ្នាំ ដោយពិនិត្យសុខភាពជាប្រចាំ ផ្តល់ថ្នាំបង្ការទាន់ពេល និងពេញលេញ ហើយតាមដានការផ្តល់សេវា អាហារូបត្ថម្ភ ចំពោះកុមារដែលខ្វះអាហារូបត្ថម្ភ មានជំងឺរ៉ាំរ៉ៃ លូតលាស់យឺត ពិការ**

- សេវាសុខភាព និងអាហារូបត្ថម្ភផ្តោតលើសេវាសមាហរណកម្មនៃការពិនិត្យ និងព្យាបាលជំងឺកុមារ និងតាមសហគមន៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាសំខាន់ៗ ពាក់ព័ន្ធជាមួយនឹងសុខភាព និងអាហារូបត្ថម្ភរបស់មាតានិងកុមារតូច។ ផែនការសកម្មភាពនេះ ស្នើឱ្យក្រសួងសុខាភិបាល និងទីភ្នាក់ងារសម្របសម្រួលរបស់ខ្លួនផ្តល់អាទិភាពជាពិសេសលើ៖
    - ការលើកកម្ពស់ការឆាប់បំបៅកូនដោយទឹកដោះម្តាយ ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់នៅក្នុងរយៈពេល ៦ ខែដំបូងនៃជីវិតរបស់ទារក ការបន្តបំបៅកូនដោយទឹកដោះម្តាយរហូតដល់កូនអាយុបាន ២ ឆ្នាំ និងការផ្តល់អាហារបន្ថែមឱ្យបានសមស្រប
    - ការធានាឱ្យមានការផ្តល់ថ្នាំបង្ការឱ្យបានទាន់ពេលវេលាដល់កុមារគ្រប់រូបប្រឆាំងនឹងជំងឺដែលអាចបង្ការបាន ដោយចាក់វ៉ាក់សាំងដូចជា៖ជំងឺរបេង ជំងឺគ្រុនស្វិតដៃជើង ជំងឺកញ្ជ្រឹល ជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស និងជំងឺរលោកថ្លើមប្រភេទបេ
    - ផ្តល់អាហារបន្ថែមប្រកបដោយជីវជាតិនិងការគាំទ្រឱ្យបានទាន់ពេលវេលាដល់កុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភ រួមផ្សំជាមួយនឹងការផ្តល់ការណែនាំអំពីសន្តិសុខស្បៀង និងសុវត្ថិភាពចំណីអាហារ
    - ធានាឱ្យមានការផ្តល់នូវមីក្រូសារជាតិសំខាន់ៗតាមរយៈមណ្ឌលសុខភាព ឬ តាមរយៈការលក់អាហារ មានបន្ថែមសារជាតិចិញ្ចឹមនៅទូទាំងប្រទេស
    - ការផ្តល់ថ្នាំទម្លាក់ព្រូនតាមរយៈមណ្ឌលសុខភាពដែលមានស្រាប់ និងនៅតាមសាលារៀន។
- ការបង្កើតយន្តការសម្របសម្រួលឱ្យបានរឹងមាំជាមួយប៉ុស្តិ៍សុខភាព មណ្ឌលសុខភាពនៅតាមឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ដែលមានស្រាប់ទាំងអស់ជាមួយនឹងសេវាពាក់ព័ន្ធនានា ដើម្បីធានាយ៉ាងណាឱ្យកុមារគ្រប់រូបអាចទទួលបាននូវការពិនិត្យការពារសុខភាព ថ្នាំបង្ការ ការថែទាំកុមារដែលមានជំងឺ និងការផ្តល់អាហារូបត្ថម្ភបន្ថែមជាទៀងទាត់ទៅតាមការចាំបាច់

- ការគាំទ្រលើកទឹកចិត្តផ្នែកចិត្តសង្គម និងការស្តារស្ថានភាពអាហារូបត្ថម្ភឡើងវិញឱ្យបានឆាប់រហ័សសម្រាប់កុមារដែលមានតម្រូវការពិសេសផ្នែកអាហារូបត្ថម្ភ ដូចជាកុមារស្គមស្គាំង និងកុមារមិនគ្រប់ទម្ងន់
- ការផ្តល់ការគាំពារផ្នែកសុខភាពជាពិសេសចំពោះកុមារពិការ កុមារមានការលូតលាស់យឺត មានជំងឺរ៉ាំរ៉ៃ កុមារជនជាតិដើមភាគតិច និងកុមារបាត់បង់ឱកាស
- ការអប់រំមាតាបិតាអំពីការចិញ្ចឹមបីបាច់កូនឱ្យបានល្អ ដោយផ្តោតជាពិសេសលើការអប់រំអំពីអាហារូបត្ថម្ភនិងសុខភាព ក៏ដូចជាសកម្មភាពដែលត្រូវធ្វើជាមួយនឹងកូនស្របទៅតាមការអភិវឌ្ឍរបស់ពួកគេ
- ការចុះតាមផ្ទះនិងការចងក្រងក្រុមមាតាបិតានិងផែនការអន្តរកាល ដើម្បីផ្តល់សេវាអប់រំបញ្ចូលគ្នានៅតាមសាលាមត្តេយ្យ ឬ សាលាបឋមសិក្សា។
- ការផ្តួចផ្តើមឱ្យមានការចុះផ្សព្វផ្សាយ និងចុះផ្តល់ការអប់រំដល់មាតាបិតាអំពីលក្ខណៈសមស្របសម្រាប់ទទួលសេវាអន្តរាគមន៍ទាន់ពេលវេលា ដើម្បីកំណត់រកឱ្យឃើញកុមារដែលគួរទទួលសេវានេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ចាប់ពីពេលសម្រាលតទៅ និងដើម្បីលើកទឹកចិត្តឱ្យមាតាបិតាចុះឈ្មោះកូនរបស់ពួកគេក្នុងការទទួលសេវា។

**យុទ្ធសាស្ត្រទី៧៖** **ពង្រីកការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចរួមមាន សេវារដ្ឋ សេវាសហគមន៍ សេវាឯកជន តាមផ្ទះនិងតាមខ្នងផ្ទះ ជាពិសេសការហាត់រៀន ពីដំបូងចំពោះ កុមារតូច។**

- ការអប់រំមាតាបិតាឱ្យបានដឹងអំពីតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច និងបំពាក់បំប៉នដល់ពួកគេនូវចំណេះដឹងនិងការអនុវត្តសមស្រប ដើម្បីឱ្យពួកគេអាចផ្តល់ឱ្យកូនៗរបស់ពួកគេនូវសេវាសំខាន់ៗ និងឱកាសរៀនសូត្រដំបូង
- ការកសាងម៉ូឌុលអប់រំមាតាបិតាដែលមានលក្ខណៈជាពហុវិស័យ ដែលគ្របដណ្តប់លើសារៈសំខាន់នៃសុខភាព អាហារូបត្ថម្ភ អនាម័យ ការការពារ និងការគាំទ្រលើកទឹកចិត្តផ្នែកចិត្តសង្គម នៅក្នុងវ័យកុមារតូចដោយរក្សាសង្គតិភាពជាមួយវិស័យពាក់ព័ន្ធ និងមានលក្ខណៈស្តង់ដារ
- ការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមសហគមន៍ និងតាមផ្ទះសម្រាប់កុមារមិនអាចនៅជាមួយនឹងម្តាយ ឪពុក ឬ សមាជិកគ្រួសាររបស់ពួកគេ ដើម្បីធានាយ៉ាងណាឱ្យកុមារទទួលបានការគាំពារនិងអភិវឌ្ឍន៍បានល្អ
    - សេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមមណ្ឌល ដែលផ្តល់ដោយវិស័យសាធារណៈ និងវិស័យឯកជន និងដោយអង្គការសង្គមស៊ីវិល

- សេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមផ្ទះសម្រាប់ថែទាំកុមារតាមគ្រួសារ ដោយមានការគ្រប់គ្រងដោយគ្រួសារមិត្តភក្តិ ឬ អ្នកជិតខាងសម្រាប់កុមារមកពី ២ គ្រួសារឡើងទៅ
    - ការអនុវត្តវិមជ្ឈការក្នុងការផ្តល់សេវាអប់រំនិងអភិវឌ្ឍសម្រាប់កុមារអាយុពី ០ ដល់ ៣ ឆ្នាំ នៅថ្នាក់ក្រោមជាតិ
    - ការកំណត់ស្តង់ដារអប្បបរមា និងការទទួលស្គាល់គុណភាពដល់មណ្ឌលគាំពារនិងអភិវឌ្ឍកុមារតូច
    - ការរៀបចំផែនទីតម្រូវការសេវា ដោយកំណត់ទីតាំងនិងចំនួនប្រជាជនដែលមានតម្រូវការសេវាតាមលំដាប់អាទិភាព ដែលជាមូលដ្ឋានសម្រាប់ព្យាករណ៍ថវិកាដែលត្រូវមាន និងដើម្បីផ្តល់សេវាដល់ប្រជាជនតាមគោលដៅ
    - ការផ្តោតការយកចិត្តទុកដាក់លើកុមារដែលប្រឈមនឹងហានិភ័យខ្ពស់ដូចជា ១)កុមារកំព្រាកុមារបាត់បង់ឱកាស និងកុមារដែលនៅបែកពីគ្រួសារតាមរយៈផ្តល់ការចិញ្ចឹមបីបាច់ឱ្យបានល្អ ធានានូវការថែទាំសុខភាពនិងអាហារូបត្ថម្ភ ការការពារ និងសកម្មភាពអភិវឌ្ឍសមស្រប ដែលត្រូវផ្តល់ឱ្យពួកគេជាប្រចាំថ្ងៃ និង ២) កុមារដែលមានតម្រូវការពិសេស ដូចជា៖កុមារដែលមានបញ្ហាលូតលាស់យឺតយ៉ាវ បញ្ហាកង្វះអាហារូបត្ថម្ភ បញ្ហាពិការភាព និងបញ្ហាឥរិយាបថខុសប្រក្រតីដែលត្រូវការសេវាគាំពារ និងអភិវឌ្ឍបែបរួមបញ្ចូលគ្នា។
- ការពង្រីកសេវាអប់រំកុមារតូចគ្រប់រូបភាពនិងគ្រប់ទីកន្លែងសម្រាប់កុមារអាយុចាប់ពី ៣ ឆ្នាំ ដល់ ក្រោម ៦ ឆ្នាំ ជាពិសេសតំបន់ដែលមានអត្រាចូលរៀនថ្មីនិងអត្រាពិតនៃការសិក្សាទាប អត្រាបោះបង់ការសិក្សាខ្ពស់ និងតំបន់ដែលមានស្ថានភាពអាហារូបត្ថម្ភ ការគាំពារកិច្ចការពារកុមារ និងការប្រើប្រាស់សេវាសុខាភិបាលនៅទាប
- ពង្រឹងនិងពង្រីកមត្តេយ្យសិក្សាសហគមន៍ពីរភាសាសម្រាប់តំបន់ជនជាតិដើមភាគតិច
- ពង្រីកកម្មវិធីអប់រំបញ្ចូលគ្នា សម្រាប់កុមារមានពិការភាព នៅតាមសាលាមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍
- ការស្វែងរកការគាំទ្រ ដើម្បីផ្តល់ឱ្យសាលាមត្តេយ្យ ឬ មណ្ឌលគាំពារនិងអភិវឌ្ឍកុមារតូចដែលទទួលយកកុមារមកពីគ្រួសារដែលមានចំណូលទាបបានចូលរៀន និងទទួលសេវាផ្តល់អាហារតាមសាលារៀន
- ការសាងសង់និងពង្រីកសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសិក្សាសហគមន៍ និងសាលាមត្តេយ្យសិក្សាធនធាន ឱ្យស្របតាមស្តង់ដារគុណភាពដោយបំពាក់សម្ភារបរិក្ខារ ផ្នែកអនាម័យទឹកស្អាត កន្លែងលាងសម្អាតដៃ ប្រអប់សង្គ្រោះបឋម និងរៀបចំទីធ្លាសម្រាប់ការលេងរបស់កុមារ

- ការបង្កើនថវិកាចំណាយលើការគាំពារ និងអភិវឌ្ឍកុមារតូចនៅក្នុងថវិកាអភិវឌ្ឍឃុំ សង្កាត់ និងប្រភពផ្សេងទៀត តាមរយៈសមាហរណកម្មផែនការជាមួយគ្នារវាងវិស័យសាធារណៈ វិស័យឯកជន និងអង្គការសង្គមស៊ីវិល
- សិក្សាលទ្ធភាពក្នុងការជំរុញឱ្យរោងចក្រសហគ្រាសរៀបចំសេវាគាំពារនិងអភិវឌ្ឍកុមារតូច សម្រាប់កម្មករនិងនិយោជិកដែលមានកូនតូច
- បញ្ចូលការពិនិត្យសុខភាព ការផ្តល់សារធាតុចិញ្ចឹម ថ្នាំគ្រាប់បញ្ចុះព្រូន និងការចាក់វ៉ាក់សាំងតាមរយៈកម្មវិធីអប់រំកុមារតូចដែលមានស្រាប់ និងការបង្កើតប្រព័ន្ធបញ្ជូនទៅកាន់មណ្ឌលសុខភាព។

**យុទ្ធសាស្ត្រទី ៨៖ ធានាឱ្យគ្រប់គ្រួសារទទួលបានព័ត៌មាន និងសេវាដូចជា ទឹកស្អាត និងអនាម័យ សុខភាព អាហារូបត្ថម្ភ ការបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់អាហារបន្ថែម ការទទួលថ្នាំបង្ការ ជីវជាតិអា ជាតិដែក និងអំបិលអ៊ីយ៉ូដ ការរៀនពីដំបូង ការចុះបញ្ជីកំណើត ការទប់ស្កាត់ជំងឺឆ្លងគ្រប់ ប្រភេទមានជាអាទិ៍ មេរោគអេដស៍និងជំងឺអេដស៍ ជំងឺគ្រុនចាញ់ ការការពារគ្រួសារពីអំពើហិង្សា និង ការរងគ្រោះដោយប្រការផ្សេងៗ។**

- ការផ្តល់ព័ត៌មានដល់មាតាបិតា និងកុមារអំពីទម្លាប់អនាម័យបរិស្ថាន អនាម័យខ្លួនប្រាណ និងកន្លែងដែលពួកគេអាចទទួលបានសេវាអនាម័យទាំងនេះតាមរយៈការកសាង និងប្រើប្រាស់បង្គន់អនាម័យ ឬ បរិក្ខារសម្រាប់សម្អាត និងការរក្សាទុកទឹកប្រើប្រាស់ក្នុងគ្រួសារ
- ការផ្តល់ព័ត៌មានដល់សហគមន៍អំពីទម្លាប់អនាម័យបរិស្ថាន ដើម្បីកាត់បន្ថយការបំពុលបរិស្ថានក្នុងសហគមន៍ ដែលកើតឡើងដោយសារការប្រើប្រាស់ធនធានទឹករួមគ្នា
- ការបំពាក់បរិក្ខារនិងការផ្គត់ផ្គង់ទឹកស្អាតនិងបង្គន់អនាម័យ នៅតាមសាលារៀននិងទីសាធារណៈ និងទម្លាប់លាងសំអាតដៃជាមួយសាប៊ូ និងការដុសធ្មេញរបស់កុមារ
- ការរៀបចំម៉ូឌុលបណ្តុះបណ្តាលអំពីទឹកស្អាត ជម្រើសសម្រាប់សម្អាតទឹក និងរក្សាទុកទឹកប្រកបដោយសុវត្ថិភាពនៅតាមគ្រួសារនិងសហគមន៍
- ការសាងសង់និងការជួសជុលបង្គន់ជាលក្ខណៈមូលដ្ឋាន និងការផ្តល់ប្រាក់សម្រាប់សាងសង់បង្គន់អនាម័យ
- ការផ្សព្វផ្សាយនិងទទួលព័ត៌មានពីការផ្តល់សេវាថែទាំសុខភាព និងអាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះនិងកុមារតាមរយៈប្រព័ន្ធផ្សព្វផ្សាយ សៀវភៅ ផ្ទាំងរូបភាព និងសៀវភៅណែនាំ
- ការបង្កើនការយល់ដឹងអំពីសារៈសំខាន់និងតម្រូវការនៃការចុះសំបុត្រកំណើត តាមរយៈការចុះផ្សព្វផ្សាយប្រចាំខែ និងតាមរយៈសារអប់រំខ្លីៗ

- ការរៀបចំឱ្យមានឧបករណ៍សម្ភារៈសម្រាប់ផ្តល់សំបុត្រកំណើតឱ្យបានគ្រប់គ្រាន់ នៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ
- ការពង្រឹងបន្ថែមលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់អំពីការចុះអត្រានុកូលដ្ឋាន និងលុបបំបាត់ការប្រមូលថ្លៃសេវាក្រៅផ្លូវការ
- ការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនឹងសេវាសុខភាព និងសកម្មភាពនានា ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការចុះសំបុត្រកំណើតដល់ទារក
- ការរៀបចំយន្តការដើម្បីធានាសុវត្ថិភាព ការបង្ការការរងរបួស និងការសង្គ្រោះបឋម
- ការធានាថាកុមារអាយុពី ០ ដល់ក្រោម ៦ ឆ្នាំ ដែលកំពុងរងគ្រោះរស់នៅតាមទីសាធារណៈ ឬ តាមមណ្ឌលផ្តល់ការថែទាំ ត្រូវចាត់ទុកថាជាក្រុមគោលដៅអាទិភាព សម្រាប់ការគ្រប់គ្រងករណីការស្វែងរកគ្រួសារ ការធ្វើសមាហរណកម្ម និងការរៀបចំផែនការសម្រាប់ការតាំងទីលំនៅអចិន្ត្រៃយ៍
- ការកសាងសមត្ថភាពរបស់ភ្នាក់ងារសង្គមកិច្ច មាតាបិតា និងអ្នកផ្តល់ការថែទាំតាមសហគមន៍អំពីការកំណត់ និងការបញ្ជូនករណីអំពើហិង្សាលើកុមារទៅរកសេវាឯកទេសផ្សេងៗ
- ការរៀបចំកម្មវិធីអប់រំមាតាបិតា ដើម្បីបង្កើនការយល់ដឹងអំពីទម្លាប់ចិញ្ចឹមកូនជាលក្ខណៈវិជ្ជមាននិងមិនលើកទឹកចិត្តពួកគេឱ្យដាក់វិន័យលើកុមារហួសហេតុ ឬ ដែលអាចនាំឱ្យមានគ្រោះថ្នាក់ និងការប៉ះពាល់ដែលមិនសមស្រប
- ការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ដែលមានផលប៉ះពាល់លើសមាជិកគ្រប់រូបនៅក្នុងគ្រួសារ ជាពិសេសនាំឱ្យមានផលប៉ះពាល់ខ្លាំងជាងគេលើម្តាយ និងកុមារតូច ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានពេញមួយជីវិត
- ការបង្កើនការផ្សព្វផ្សាយការយល់ដឹងអំពីសិទ្ធិរបស់កុមារ នៅតាមសាលារៀន ទីសាធារណៈ និងសហគមន៍
- ការរៀបចំនិងកែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ។

### **យុទ្ធសាស្ត្រទី ៩៖** បង្កើតឱ្យមានយន្តការផ្សព្វផ្សាយព័ត៌មានអំពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចសម្រាប់ទាក់ទាញការគាំទ្រសេវាទាំងនោះ។

- ការផ្សព្វផ្សាយព័ត៌មានអំពីការគាំពារនិងអភិវឌ្ឍកុមារតូចឱ្យបានទូលំទូលាយ ដោយប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់រូបភាពទាំងអស់រួមទាំងវិទ្យុ ទូរទស្សន៍ និងការបង្កើតគេហទំព័រ និងប្រព័ន្ធទំនាក់ទំនងសង្គម និងព្រឹត្តិបត្តិព័ត៌មាន

- ការបង្កើតកម្មវិធីប្រាស្រ័យទាក់ទង តាមរយៈការពិគ្រោះយោបល់កម្រិតគោលនយោបាយ ប្រព័ន្ធផ្សព្វផ្សាយសង្គម វេទិកាសហគមន៍ និងការប្រាស្រ័យទាក់ទងអន្តរបុគ្គលតាមរូបភាពផ្សេងៗដូចជា សិក្ខាសាលាអំពីគំនិតផ្តួចផ្តើមសំខាន់ៗសម្រាប់ថ្នាក់ដឹកនាំនិងអ្នកពាក់ព័ន្ធ កិច្ចពិភាក្សាតុមូលកម្រិតជាតិនិងអន្តរជាតិដើម្បី៖
    - ជំរុញឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីអ្នកតាក់តែងគោលនយោបាយ ដើម្បីឱ្យមានការប្តេជ្ញាចិត្តរួមគ្នាចំពោះការងារគាំពារនិងអភិវឌ្ឍន៍កុមារតូច
    - បង្កើនការយល់ដឹងរបស់មាតាបិតា និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ ដើម្បីជំរុញលើកទឹកចិត្តឱ្យមានតម្រូវការសេវាគាំពារនិងអភិវឌ្ឍកុមារតូចដែលប្រសើរជាងមុន និងលើកកម្ពស់ស្មារតីភាពជាម្ចាស់ ។
- អគ្គលេខាធិការដ្ឋានគាំពារនិងអភិវឌ្ឍកុមារតូច ត្រូវធ្វើការស្រាវជ្រាវបឋម បូកសរុបលទ្ធផលវេទិកាពិគ្រោះយោបល់ដោយធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាលើ៖
    - ការពិនិត្យមើលឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយលើការអនុវត្តបច្ចុប្បន្ននៅតាមវិស័យដើម្បីកំណត់ពីបញ្ហាប្រឈមនិងលើកនូវអនុសាសន៍សំខាន់ៗ
    - ការផ្តល់ព័ត៌មានត្រឡប់ដើម្បីដាក់បញ្ចូលអនុសាសន៍ទៅក្នុងការរៀបចំផែនការសកម្មភាពតាមវិស័យ
    - ការពិនិត្យតាមដានលើដំណើរការនៃការអនុវត្តផែនការសកម្មភាពសម្រាប់ផ្តល់ការគាំទ្រនិងកៀរគរធនធានបន្ថែម។



# ៣. ផែនការសកម្មភាព

## ៣. ផែនការសកម្មភាព

**យុទ្ធសាស្ត្រទី ១ ៖** រៀបចំក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការ ដើម្បីគាំទ្រនិងអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាពដោយកំណត់ឱ្យមានកិច្ចសហការ និងភារកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ៖

| ល.រ | យុទ្ធសាស្ត្រវង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្របដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលា កំណត់ | អ្នកទទួល ខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | ធានានិរន្តរភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធការងាររបស់គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច | ○ ជំរុញក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានា ដើម្បីអនុវត្តតួនាទី ភារកិច្ច ដែលមានចែងក្នុងគោលនយោបាយស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច<br>○ ជំរុញនិងសម្របសម្រួលដល់គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធរៀបចំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ | • សេចក្តីណែនាំ លិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តតួនាទី និងភារកិច្ច<br>• សេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ | ២០១៩-២០១៨ | គ.ជ.គ.ក. | 25,000.00 |
| | | ⊖ ជំរុញនិងសម្របសម្រួលការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិ | • សេចក្តីណែនាំនិងផែនការប្រតិបត្តិដើម្បីអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិ | ២០១៩-២០១៨ | គ.ជ.គ.ក. ដៃគូអភិវឌ្ឍ | 60,000.00 |
| | | ○ សហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់ | • ២០%ក្នុង១ឆ្នាំនៃរាជធានី | ២០១៩- | គ.ជ.គ.ក. | 500,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | | កិច្ចការស្ត្រីនិងកុមារនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់លើការរៀបចំផែនការសកម្មភាពការអនុវត្ត និងការពិនិត្យតាមដានការគាំពារនិងអភិវឌ្ឍន៍កុមារតូច | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់មានផែនការសកម្មភាពគាំពារនិងអភិវឌ្ឍកុមារតូច | ២០១៨ | ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | |
| | | ○ អនុម័តនិងផ្សព្វផ្សាយគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចដល់ក្រសួង ស្ថាប័ន អង្គការជាតិនិងអន្តរជាតិនិងដៃគូអភិវឌ្ឍពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | • ចំនួនមន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិចូលរួមសិក្ខាសាលាផ្សព្វផ្សាយគោលនយោបាយជាតិ ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច | ២០១៤-២០១៨ | គ.ជ.គ.ក. ដៃគូអភិវឌ្ឍ | 210,000.00 |
| | | ○ រៀបចំក្របខណ្ឌច្បាប់សម្រាប់អនុវត្តកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូច | • លិខិតបទដ្ឋានគោលការណ៍ណែនាំអនុវត្តកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូចតាមវិស័យ | ២០១៤-២០១៨ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 15,000.00 |
| | | ○ បង្កើតយន្តការស្រាវជ្រាវ ដើម្បីកំណត់អត្តសញ្ញាណ ស្វែងរក និងពិនិត្យមើលទាន់ពេលវេលាសម្រាប់កុមារតូចដែលមានតម្រូវការពិសេសនិងពិការភាព | • ក្របខណ្ឌការងារកំណត់អត្តសញ្ញាណកុមារតូចដែលមានតម្រូវការពិសេសនិងពិការភាពបានរៀបចំ | ២០១៤-២០១៨ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 20,000.00 |
| | | ○ រៀបចំយន្តការគាំទ្រសេវារដ្ឋ សេវាសហគមន៍ | • ក្របខណ្ឌការងារគាំទ្រ | ២០១៤- | គ.ជ.គ.ក. | 50,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | | សេវាឯកជនតាមផ្ទះ និងតាមខ្នងផ្ទះ ក្នុងការផ្តល់សេវា គាំពារនិងអភិវឌ្ឍកុមារតូច ដោយយកចិត្តទុកដាក់ ចំពោះកុមារដែលរស់នៅក្នុងតំបន់ជួបការលំបាក កុមារជនជាតិដើមភាគតិច និងកុមារបាត់បង់ឱកាស | សេវារដ្ឋ សេវាសហគមន៍ សេវាឯកជនតាមផ្ទះ និងតាមខ្នងផ្ទះ ក្នុងការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចបានរៀបចំ | ២០១៨ | ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | |
| | | ○ កៀរគរធនធានសម្រាប់គាំទ្រការអនុវត្តការគាំពារនិងអភិវឌ្ឍន៍កុមារតូច | • ភាគរយថវិកាសម្រាប់គាំពារនិងអភិវឌ្ឍកុមារតូចកើនឡើង | ២០១៥-២០១៨ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 10,000.00 |
| | | ○ ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការគាំពារ និងអភិវឌ្ឍកុមារតូចដើម្បីដាក់ជូនរាជរដ្ឋាភិបាល | • របាយការណ៍ស្តីពីវឌ្ឍនភាពនៃការគាំពារនិងអភិវឌ្ឍកុមារតូចបានរៀបចំ | ២០១៥-២០១៨ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ | 10,000.00 |
| ២ | ធានានិរន្តភាព និងប្រសិទ្ធភាពការងាររបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូចមានភារកិច្ច | ○ គ្រប់គ្រងកិច្ចការរដ្ឋបាលនិងបច្ចេកទេសដែលធានាបាននូវការប្រព្រឹត្តទៅប្រកបដោយនិរន្តរភាពរបស់គ.ជ.គ.ក. | • ផែនការការងារសម្រាប់កិច្ចដំណើរការអគ្គលេខាធិការដ្ឋាន គ.ជ.គ.ក. | ២០១៥-២០១៨ | អគ្គលេខាធិការដ្ឋាន គ.ជ.គ.ក. | 50,000.00 |
| | | ○ ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលទទួលបានការយល់ព្រមពីគ.ជ.គ.ក. ដល់គ្រប់ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ | • មន្ត្រីក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធទទួលការផ្សព្វផ្សាយ<br>• លិខិតបទដ្ឋានគតិយុត្តផ្សេងៗ | ២០១៥-២០១៨ | អគ្គលេខាធិការដ្ឋាន គ.ជ.គ.ក. | 50,000.00 |
| | | ○ អភិវឌ្ឍនិងពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ | • ផែនការថវិកា និង | ២០១៥- | អគ្គលេខា | 50,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | | របស់ គ.ជ.គ.ក. | របាយការណ៍ចំណូលចំណាយហិរញ្ញវត្ថុរបស់ គ.ជ.គ.ក. បានរៀបចំ | ២០១៨ | ធិការដ្ឋាន គ.ជ.គ.ក. | |
| | | ○ លើកសំណើសុំពិនិត្យនិងកែលម្អគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូចជូន គ.ជ.គ.ក. | • ការឯកភាពពីគ.ជ.គ.ក. លើសំណើសុំពិនិត្យនិងកែលំអគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច | ២០១៤-២០១៨ | អគ្គលេខាធិការដ្ឋាន គ.ជ.គ.ក. | 5,000.00 |
| ៣ | កំណត់និងបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ | ○ រៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ | • លិខិតបទដ្ឋានគតិយុត្តបានរៀបចំ | ២០១៤ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ | 2,000.00 |
| | | ○ រៀបចំផែនការសកម្មភាពនិងផែនការថវិកាតាមវិស័យដើម្បីបញ្ចូលក្នុងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច | • ផែនការសកម្មភាពនិងផែនការថវិកាបានរៀបចំ | ២០១៤ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ | 15,000.00 |
| | | ○ រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារនិងផ្ញើជូនគ.ជ.គ.ក. | • របាយការណ៍បានរៀបចំតាមការកំណត់ | ២០១៤-២០១៨ | ក្រ.ពាក់ព័ន្ធ | 10,000.00 |
| ៤ | ពង្រឹងការអនុវត្តប្រព័ន្ធការងារគាំពារ និង អភិវឌ្ឍកុមារតូចតាមបែប វិមជ្ឈការ | ○ ជំរុញការអនុវត្តនិងពិនិត្យតាមដានការអនុវត្តការងារគាំពារនិងអភិវឌ្ឍកុមារតូចតាមបែបវិមជ្ឈការ | • របាយការណ៍វឌ្ឍនភាពនិងរបាយការណ៍ពិនិត្យតាមដាន | ២០១៤-២០១៨ | ក្រ.ពាក់ព័ន្ធ | 50,000.00 |

**យុទ្ធសាស្ត្រទី ២ ៖** កែលម្អយន្តការតាមដានវាយតម្លៃ ដែលមានស្រាប់ឬបង្កើតថ្មី ដោយមានការចូលរួមពីក្រសួង ស្ថាប័ន សហគមន៍ ដៃគូអភិវឌ្ឍនានា និងកែលម្អគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយបែងចែកភារកិច្ចនិងការទទួលខុសត្រូវឱ្យបានច្បាស់លាស់

| ល.រ | យុទ្ធសាស្ត្រង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្រប់ដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលា កំណត់ | អ្នកទទួលខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | រៀបចំនិងកែលម្អយន្តការពិនិត្យតាមដាននិងវាយតម្លៃការគាំពារនិងអភិវឌ្ឍកុមារតូចតាមវិស័យរួម និងតាមវិស័យពាក់ព័ន្ធ | ○ រៀបចំប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃសេវាគាំពារនិងអភិវឌ្ឍកុមារតូចរួម | • ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃសេវាគាំពារនិងអភិវឌ្ឍកុមារតូចរួម | ២០១៤-២០១៨ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 20,000.00 |
| | | ○ រៀបចំប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃសេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមវិស័យ | • ក្របខណ្ឌពិនិត្យតាមដាននិងវាយតម្លៃសេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមវិស័យពាក់ព័ន្ធ | ២០១៤-២០១៨ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 26,500.00 |
| | | ○ ពិនិត្យតាមដានវាយតម្លៃនិងធ្វើរបាយការណ៍នៅគ្រប់កម្រិតទាំងអស់ចាប់ពីថ្នាក់ឃុំ សង្កាត់ | • ផែនការពិនិត្យតាមដាននិងវាយតម្លៃត្រូវបានរៀបចំនិងរបាយការណ៍លទ្ធផលនៃការពិនិត្យតាមដានត្រូវបានរៀបចំគ្រប់កម្រិត | ២០១៤-២០១៨ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 124,000.00 |
| | | ○ របៀបរបបរបាយការណ៍និងចងក្រងប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំសម្រាប់ដាក់ជូនគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច | • របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឆមាសនិងប្រចាំឆ្នាំត្រូវបានរៀបចំ | ២០១៤-២០១៨ | គ.ជ.គ.ក. ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 10,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | | ○ មូលដ្ឋានទិន្នន័យនឹងត្រូវពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នកម្មរៀងរាល់ ៥ ឆ្នាំ<br>○ ដាក់បញ្ចូលក្នុងគោលដៅសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃ សេវាគាំពារ និងអភិវឌ្ឍកុមារតូចដែលអនុវត្តដោយដៃគូអភិវឌ្ឍ អង្គការជាតិ និងសង្គមស៊ីវិល | • ព័ត៌មានទិន្នន័យមូលដ្ឋាននិងបច្ចុប្បន្នភាពទិន្នន័យត្រូវបានរៀបចំ<br>• ព័ត៌មានមូលដ្ឋានត្រូវបានរៀបចំឡើងដោយផ្អែកលើរបាយការណ៍វឌ្ឍនភាព របាយការណ៍ពាក់កណ្តាលអាណត្តិ | ២០១៤-២០១៨ | អគ្គលេខាធិការដ្ឋាន គ.ជ.គ.ក. | 20,000.00 |

**យុទ្ធសាស្ត្រទី ៣ ៖ កសាងសមត្ថភាព (បណ្តុះបណ្តាលមុន និងកំពុងបម្រើការងារ) អ្នកអនុវត្តកម្មវិធី មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាកុមារលើខ្លឹមសារ និងវិធីថែទាំឱ្យស្របតាម កម្មវិធីសិក្សានិងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។**

| ល.រ | យុទ្ធសាស្ត្ររង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្រប់ដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលាកំណត់ | អ្នកទទួលខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | ការបណ្តុះបណ្តាលនិងវិក្រឹតការសម្រាប់អ្នកផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច | ○ ការបណ្តុះបណ្តាលអ្នកគ្រប់គ្រងនិងវិក្រឹតការបុគ្គលិកលើកិច្ចគាំពារនិងអភិវឌ្ឍកុមារតូច | • ចំនួនបុគ្គលិកគាំពារនិងអភិវឌ្ឍកុមារតូចបានទទួលការបណ្តុះបណ្តាល | ២០១៤-២០១៨ | ក្រ.អយក | 400,000.00 |
| ២ | ប្រព័ន្ធបណ្តុះបណ្តាលនិងវិក្រឹតការនៅថ្នាក់ជាតិនឹងត្រូវបង្កើតឡើងដើម្បីអនុវត្តនៅតាមស្ថាប័នបណ្តុះបណ្តាលដែលមានស្រាប់ | ○ សិក្សានិងពិនិត្យមើលវឌ្ឍនភាពនៃការគាំពារនិងអភិវឌ្ឍន៍កុមារតូច | • របាយការណ៍សិក្សានិងវឌ្ឍនភាពនៃកិច្ចគាំពារនិងអភិវឌ្ឍកុមារតូចត្រូវបានរៀបចំផ្សព្វផ្សាយ | ២០១៤-២០១៨ | ក្រ.អយក<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 10,000.00 |
| | | ○ រៀបចំកម្មវិធីសិក្សានិងឯកសារសម្រាប់បណ្តុះបណ្តាលនិងវិក្រឹតការជំនាញគាំពារនិងអភិវឌ្ឍកុមារតូចស្របតាមកម្មវិធីសិក្សាជាតិនិងកម្មវិធីសិក្សារបស់បណ្តាប្រទេសក្នុងតំបន់ | • កម្មវិធីសិក្សានិងឯកសារសម្រាប់បណ្តុះបណ្តាលនិងវិក្រឹតការជំនាញគាំពារនិងអភិវឌ្ឍកុមារតូច | ២០១៤ | ក្រសួង<br>អ.យ.ក | 40,000.00 |
| ៣ | រៀបចំនីតិវិធីនិងក្រមសីលធម៌សម្រាប់អ្នកផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច | ○ រៀបចំនីតិវិធី និងក្របខណ្ឌអនុវត្ត | • លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្រមសីលធម៌ស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចត្រូវបានរៀបចំឡើង | ២០១៤-២០១៨ | គ.ជ.គ.ក.<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 5,000.00 |

## យុទ្ធសាស្ត្រទី៤៖ បង្កើតយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីផ្តល់វិញ្ញាបនបត្រឬលិខិតទទួលស្គាល់ដល់អ្នកអនុវត្តកម្មវិធីទៅតាមសេវាថៃទាំជាក់ស្តែង

| ល.រ | យុទ្ធសាស្ត្រវង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្រប់ដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលា កំណត់ | អ្នកទទួល ខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | ការផ្តល់នូវសញ្ញាបត្រនិងវិញ្ញាបនបត្រដល់អ្នកបានឆ្លងការបណ្តុះបណ្តាលនិងវិក្រឹតការតាមគ្រប់រូបភាព | ○ កំណត់ស្តង់ដារស្ថាប័នបណ្តុះបណ្តាលនិងកម្មវិធីបណ្តុះបណ្តាលនិងទទួលស្គាល់គុណភាពបណ្តុះបណ្តាលសេវាគាំពារនិងអភិវឌ្ឍកុមារតូចនៅគ្រប់រូបភាព | • សៀវភៅណែនាំស្តីពីស្តង់ដារ ស្ថាប័នបណ្តុះបណ្តាល និងកម្មវិធីបណ្តុះបណ្តាល និងទទួលស្គាល់គុណភាពបណ្តុះបណ្តាលសេវាគាំពារនិងអភិវឌ្ឍកុមារតូចនៅគ្រប់រូបភាពត្រូវបានរៀបចំ | ២០១៤-២០១៨ | ក្រ.អយក ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 20,000.00 |
| | | ○ ការផ្តល់វិញ្ញាបនបត្រដល់អ្នកដែលបានបញ្ចប់ការបណ្តុះបណ្តាលនិងវិក្រឹតការមុខជំនាញ | • ចំនួនអ្នកបណ្តុះបណ្តាលបានទទួលវិញ្ញាបនបត្រ | ២០១៤-២០១៨ | ក្រ.អយក ក្រ.ពាក់ព័ន្ធ | 50,000.00 |
| | | ○ ការរៀបចំមូលដ្ឋានទិន្នន័យគ្រប់គ្រងអ្នកដែលបានទទួលសញ្ញាបត្រ ឬ វិញ្ញាបនបត្រ | • មូលដ្ឋានទិន្នន័យគ្រប់គ្រងអ្នកដែលបានទទួលសញ្ញាបត្រឬវិញ្ញាបនបត្រត្រូវបានរៀបចំ | ២០១៤-២០១៨ | ក្រ.អយក ក្រ.ពាក់ព័ន្ធ | 5,000.00 |

**យុទ្ធសាស្ត្រទី ៥៖ បង្កើនសេវានិងការអប់រំស្តីអំពីការថែទាំសុខភាពនិងអាហារូបត្ថម្ភដល់ស្ត្រីទាំងអស់ដែលមានផ្ទៃពោះ**

| ល.រ | យុទ្ធសាស្ត្រវង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្របដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលា កំណត់ | អ្នកទទួល ខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | ការផ្សព្វផ្សាយអំពីការរៀបចំផែនការគ្រួសារ និងការប្រឹក្សាមុនពេលសម្រេចចិត្តមានផ្ទៃពោះ ទៅតាមការចាំបាច់ | ○ រៀបចំផែនការសម្រាប់ប្រើប្រាស់កែសម្រួល និង/ឬ រៀបចំឯកសារនានាសម្រាប់៖ ១) ការរៀបចំផែនការគ្រួសារ ២) ការអប់រំអំពីការត្រៀមមានផ្ទៃពោះ | ផែនការសម្រាប់ប្រើប្រាស់កែសម្រួល និង/ឬ រៀបចំឯកសារនានាសម្រាប់ ១) ការរៀបចំផែនការគ្រួសារ និង ២) ការអប់រំអំពីការត្រៀមមានផ្ទៃពោះត្រូវបានរៀបចំ | ២០១៥ | ក្រ. សុខាភិ បាល ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 20,000.00 |
| | | ○ ប្រើប្រាស់ឯកសារក្នុងមណ្ឌលសុខភាពនិងសេវាគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅក្នុងពេលចុះតាមផ្ទះនិងក្នុងកិច្ចប្រជុំក្រុម | • ចំនួនមណ្ឌលសុខភាព ចំនួនភូមិ ចំនួនខ្នងផ្ទះ ដែលបានផ្សព្វផ្សាយឯកសារ | ២០១៤-២០១៨ | ក្រ. សុខាភិបាល អគ្គលេខាធិការដ្ឋាន | 50,000.00 |
| | | ○ រៀបចំផែនការនិងកាលវិភាគបណ្តុះបណ្តាលបុគ្គលិកនៅមូលដ្ឋានរបស់ក្រសួងសុខាភិបាល និងបុគ្គលិក ដែលធ្វើការងារផ្នែកគាំពារនិងអភិវឌ្ឍកុមារតូចឱ្យចេះប្រើប្រាស់សម្ភារៈ និងឯកសារទាំងនេះនៅពេលចុះតាមផ្ទះនិងក្នុងពេលរៀបចំកិច្ចប្រជុំក្រុម | • ផែនការ និង កាលវិភាគបណ្តុះបណ្តាលបានរៀបចំ | ២០១៤-២០១៨ | ក្រ. សុខាភិបាល អគ្គលេខាធិការដ្ឋាន | 40,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | ការលើកកម្ពស់ការអប់រំអំពីការថែទាំផ្ទៃពោះ ការពិនិត្យផ្ទៃពោះឱ្យបានទាន់ពេលវេលានិងទៀងទាត់ | ○ រៀបចំកូនសៀវភៅនិងសម្ភារៈឧបទេសអំពីសារអប់រំសំខាន់ៗស្តីពីការថែទាំផ្ទៃពោះ ការសម្រាល ការថែទាំទារកទើបកើត និងការថែទាំសុខភាពមាតា | • ឯកសារសម្ភារៈឧបទេសបានរៀបចំ | ២០១៤-២០១៨ | ក្រ. សុខាភិបាល<br>អគ្គលេខាធិការដ្ឋាន | 50,000.00 |
| | | ○ បណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តតាមសហគមន៍ និង ធ្វើតេស្តសាកល្បងលើកម្មវិធីនៅក្នុងស្រុកសាកល្បងចំនួន ៤ នៅតាមបណ្តាខេត្តផ្សេងៗ | • ចំនួនអ្នកស្ម័គ្រចិត្តដែលបានបណ្តុះបណ្តាល | ២០១៤-២០១៨ | ក្រ. សុខាភិបាល<br>អគ្គលេខាធិការដ្ឋាន | 500,000.00 |
| | | ○ ពិនិត្យតាមដាន និងវាយតម្លៃសេវានៅតាមទីតាំងសាកល្បងនានា | • ចំនួនទីតាំងគោលដៅពិនិត្យតាមដាន | ២០១៤-២០១៨ | ក្រ. សុខាភិបាល<br>អគ្គលេខាធិការដ្ឋាន | 100,000.00 |
| ៣ | ការយល់ដឹងពីសារៈសំខាន់នៃអាហារូបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ | ○ ពង្រីកសេវាសំខាន់ៗទាំង នេះឱ្យបានឆាប់តាមដែលអាចធ្វើបានស្របទៅតាមផែនការប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល | • ចំនួនសេវាដែលបានពង្រីក | ២០១៤-២០១៨ | ក្រ. សុខាភិបាល<br>អគ្គលេខាធិការដ្ឋាន | 600,000.00 |
| | | ○ ពង្រឹងនិងពង្រីកសេវាគាំពារ និងអភិវឌ្ឍកុមារតូច សេវាថែទាំផ្ទៃពោះ សេវាថែទាំទារកទើបកើត និងសេវាអប់រំមាតាបិតានៅតាមឃុំស្រុក<br>○ លើកទឹកចិត្តស្ត្រីឱ្យប្រើប្រាស់មូលដ្ឋានសុខាភិបាល | • ចំនួនស្រុក ឃុំ ដែលបានផ្តល់សេវាជូនប្រជាជន<br>• ចំនួនស្ត្រីមានផ្ទៃពោះបានទទួលសេវា | ២០១៤-២០១៨ | ក្រ. សុខាភិ បាល<br>សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ ឃុំ និង ស្រុក | 500,000.00 |
| ៤ | ការកែលម្អទម្លាប់និង | ○ រៀបចំ និងបង្កើតឯកសារចំនួន ៣ សម្រាប់ | • ឯកសារត្រូវបានរៀបចំ | | ក្រ. សុខាភិ បាល | 25,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | តវិយាបថក្នុងការសម្រាលកូននៅក្រៅមន្ទីរពេទ្យ ឬ មណ្ឌលសុខភាព | ផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ<br>○ លើកទឹកចិត្តស្ត្រីឱ្យមកពិនិត្យផ្ទៃពោះ និងសម្រាលកូនជាមួយបុគ្គលិកជំនាញនៅ មូលដ្ឋានសុខាភិបាលរួមមាន មណ្ឌលសុខភាព និងមន្ទីរពេទ្យ | និងបោះពុម្ពផ្សព្វផ្សាយ | ២០១៤-២០១៨ | សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ឃុំ | |
| | ការលើកកម្ពស់ឱ្យមានការប្រើប្រាស់បុគ្គលិកសុខាភិបាលជំនាញ និងមូលដ្ឋានសុខាភិបាលសម្រាប់ការថែទាំពិនិត្យផ្ទៃពោះនិងការសម្រាលកូន | ○ ធ្វើតេស្តសាកល្បងសម្ភារៈអប់រំផ្សព្វផ្សាយនៅសហគមន៍ រួចកែសម្រួលពាក្យពេជន៍ និងរូបភាពមួយចំនួនឱ្យសមស្របទៅតាមភាសាតំបន់ និងផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ | • សកម្មភាពធ្វើតេស្តសាកល្បងត្រូវបានអនុវត្ត ឯកសារបានបញ្ចប់ និងផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ | ២០១៤-២០១៨ | ក្រ. សុខាភិ បាល អគ្គលេខាធិការដ្ឋាន សេវាគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ឃុំ | 50,000.00 |

**យុទ្ធសាស្ត្រទី ៦ ៖ បង្កើនសេវាថែទាំព្យាបាលសុខភាព ជំងឺ ដល់កុមារតូចចាប់ពីពេលកើតដល់អាយុ ៣ ឆ្នាំ ដោយពិនិត្យសុខភាពជាប្រចាំ ផ្តល់ថ្នាំបង្ការទាន់ពេល និងពេញលេញ ហើយតាមដានការផ្តល់សេវា អាហារូបត្ថម្ភ ចំពោះកុមារដែលខ្វះអាហារូបត្ថម្ភ មានជំងឺរ៉ាំរ៉ៃ លូតលាស់យឺត ពិការ។**

| ល.រ | យុទ្ធសាស្ត្ររង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្រប់ដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលា កំណត់ | អ្នកទទួល ខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | សេវាសុខភាពនិងអាហារូបត្ថម្ភ ផ្តោតលើសេវាសមាហរណកម្មនៃការពិនិត្យនិងព្យាបាលជំងឺកុមារ និងតាមសហគមន៍ | ○ ការលើកកម្ពស់ការបំបៅកូនដោយទឹកដោះម្តាយនៅក្នុងអំឡុងម៉ោងដំបូងបន្ទាប់សម្រាល និងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់នៅក្នុងរយៈពេល ៦ ខែដំបូង | • ភាគរយម្តាយបំបៅកូនដោយទឹកដោះម្តាយក្នុងអំឡុងម៉ោងដំបូងបន្ទាប់ពីសម្រាល | ២០១៤-២០១៨ | ក្រ. សុខាភិ បាល ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 30,000.00 |
| | | ○ ការធានាឱ្យមានការផ្តល់ថ្នាំបង្ការឱ្យបានទាន់ពេលវេលាដល់កុមារគ្រប់រូប | • ភាគរយកុមារបានទទួលថ្នាំបង្ការ | ២០១៤-២០១៨ | ក្រ.សុខាភិបាល ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 100,000.00 |
| | | ○ ផ្តល់អាហារបន្ថែមប្រកបដោយជីវជាតិ និងអាហារព្យាបាលក្នុងការគាំទ្រឱ្យបានទាន់ពេលវេលាដល់កុមារ ដែលមានបញ្ហាកង្វះអាហារូបត្ថម្ភ | • ចំនួនកុមារបានទទួលអាហារបន្ថែមសមស្របប្រកបដោយជីវជាតិនិង<br>• ចំនួនកុមារបានទទួលការ ថែទាំព្យាបាលកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរ | ២០១៤-២០១៨ | ក្រ.សុខាភិបាល ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 1,000,000.00 |
| | | ○ ធានាឱ្យមានការផ្តល់នូវមីក្រូសារជាតិសំខាន់ៗដល់កុមារ | • ចំនួនកុមារបានទទួលមីក្រូសារ ជាតិសំខាន់ៗ | ២០១៤-២០១៨ | ក្រ.សុខាភិបាល ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 200,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | | ○ ការផ្តល់ថ្នាំទម្លាក់ព្រូនតាមរយៈមណ្ឌលសុខភាព ដែលមានស្រាប់សេវាចុះមូលដ្ឋាន និងនៅតាមសាលារៀន | • ភាគរយកុមារបានទទួលថ្នាំទម្លាក់ព្រូន | ២០១៤-២០១៨ | ក្រ.សុខាភិបាល ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 180,000.00 |
| ២ | ការបង្កើតយន្តការសម្របសម្រួលឱ្យបានរឹងមាំជាមួយប៉ុស្តិ៍សុខភាពមណ្ឌលសុខភាពនៅតាមឃុំសង្កាត់ក្រុង ស្រុក ខណ្ឌ | ○ រៀបចំលិខិតបទដ្ឋាន ធនធានមនុស្ស ផែនការសកម្មភាព | • យន្តការសម្របសម្រួលត្រូវបានរៀបចំ<br>• ចំនួនមណ្ឌលសុខភាពដែលមានបុគ្គលិកតាមការណែនាំសំណុំសកម្មភាពអប្បបរមា | ២០១៤-២០១៨ | ក្រ.សុខាភិបាល ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 10,000.00 |
| ៣ | ការអប់រំមាតាបិតាអំពីការចិញ្ចឹមបីបាច់កូនចាប់ពីពេលកើតរហូតដល់អាយុ៣ឆ្នាំ ឱ្យបានល្អ | ○ រៀបចំឯកសាដំណើរការកម្មវិធី និងការបង្កើនសមត្ថភាពអ្នកអនុវត្ត និងអ្នកផ្តល់សេវាផ្ទាល់ | • ចំនួនមាតាបិតាបានចូលរួមកម្មវិធី | ២០១៤ | ក្រ.អយក | 133,989.00 |
| | | ○ ការពិនិត្យតាមដានថ្នាក់ផ្តល់សេវា | • ចំនួនខ្នងផ្ទះបានទទួលសេវានិងបានចុះពិនិត្យតាមដាន | ២០១៤-២០១៨ | ក្រ.អយក | |

**យុទ្ធសាស្ត្រទី ៧ ៖ ពង្រីកការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចរួមមាន សេវារដ្ឋ សេវាសហគមន៍ សេវាឯកជន តាមផ្ទះ និងតាមខ្នងផ្ទះ ជាពិសេសការហាត់រៀនពីដំបូងចំពោះកុមារតូច។**

| ល.រ | យុទ្ធសាស្ត្ររង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្របដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលា កំណត់ | អ្នកទទួល ខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | ការអប់រំមាតាបិតាឱ្យបានដឹងអំពីតួនាទីរបស់ខ្លួនក្នុងនាមជាអ្នកផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូច | ○ រៀបចំឯកសារដំណើរការកម្មវិធីអប់រំមាតាបិតា | • ឯកសារដំណើរការកម្មវិធីបានរៀបចំ | ២០១៤ | ក្រ.អយក ក្រសួងកិច្ចការនារី ដៃគូអភិវឌ្ឍ | 50,000.00 |
| ២ | ការកសាងម៉ូឌុលអប់រំមាតាបិតាដែលមានលក្ខណៈជាពហុវិស័យ | ○ រៀបចំម៉ូឌុលសម្រាប់បណ្តុះបណ្តាលអ្នកអនុវត្តផ្ទាល់ | • ម៉ូឌុលសម្រាប់បណ្តុះបណ្តាលបានរៀបចំ | ២០១៤ | ក្រ.អយក ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 35,000.00 |
| ៣ | ការផ្តល់សេវាគាំពារ និងអភិវឌ្ឍកុមារតូចតាមសហគមន៍ និងតាមផ្ទះ | ○ ដំណើរការកម្មវិធីអប់រំមាតាបិតាផ្សារភ្ជាប់មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ | • ចំនួនសាលាមត្តេយ្យសិក្សា រដ្ឋមត្តេយ្យសិក្សាសហគមន៍បានអនុវត្តកម្មវិធីអប់រំមាតាបិតា | ២០១៤-២០១៨ | ក្រ.អយក ក្រ. សេដ្ឋកិច្ច ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 5,695,321.00 |
| | | ○ សេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមផ្ទះសម្រាប់ថៃទាំកុមារតាមគ្រួសារ | • ចំនួនសេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមផ្ទះត្រូវបានបង្កើត | ២០១៤ | ក្រ.អយក ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 1,582,190.00 |
| | | ○ សេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមមណ្ឌលដែលផ្តល់ដោយវិស័យសាធារណៈ វិស័យឯកជន | • ចំនួនសេវាបានបង្កើត | ២០១៤ | ក្រ.អយក ក្រ.សង្គមកិច្ច ដៃគូអភិវឌ្ឍ | 10,000,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | | និងអង្គការសង្គមស៊ីវិល | | | | |
| | | ○ ការអនុវត្តវិមជ្ឈការក្នុងការផ្តល់សេវាអប់រំនិងអភិវឌ្ឍសម្រាប់កុមារអាយុពី ០ ដល់ ៣ ឆ្នាំ នៅថ្នាក់ក្រោមជាតិ | • ចំនួនសេវាអប់រំនិងអភិវឌ្ឍសម្រាប់កុមារអាយុពី ០ ដល់ ៣ ឆ្នាំ នៅថ្នាក់ក្រោមជាតិបានអនុវត្តបែបវិមជ្ឈការ | ២០១៤ | ក្រ.អយក<br>ក្រ.សេដ្ឋកិច្ច<br>ដៃគូអភិវឌ្ឍ | 50,000.00 |
| | | ○ ការកំណត់ស្តង់ដារអប្បបរមានិងការទទួលស្គាល់គុណភាពដល់មណ្ឌលគាំពារនិងអភិវឌ្ឍកុមារតូច | • ស្តង់ដារអប្បបរមាបានកំណត់ | ២០១៤ | ក្រ.អយក<br>ដៃគូអភិវឌ្ឍ | 403,376.00 |
| | | ○ ការរៀបចំផែនទីតម្រូវការសេវាគាំពារនិងអភិវឌ្ឍកុមារតូច | • ផែនទីតម្រូវការសេវាគាំពារនិងអភិវឌ្ឍកុមារតូចបានរៀបចំ | ២០១៤ | ក្រ.អយក<br>ដៃគូអភិវឌ្ឍ | 30,000.00 |
| | | ○ ការផ្តោតការយកចិត្តទុកដាក់លើកុមារដែលប្រឈមនឹងហានិភ័យខ្ពស់ | • ចំនួនកុមារដែលប្រឈមនឹងហានិភ័យខ្ពស់បានទទួលការគាំពារ | ២០១៤-២០១៨ | ក្រ.អយក<br>ដៃគូអភិវឌ្ឍ | 100,000.00 |
| | | ○ ការបង្កើនផលិតភាពកសិកម្មតាមធនធានដែលមានឱ្យអស់លទ្ធភាពរួមទាំងការអភិវឌ្ឍសួនបន្លែ ការចិញ្ចឹមសត្វ និងដំណាំចម្រុះជុំវិញគេហដ្ឋាន | • ចំនួនគេហដ្ឋានដែលមានសួនបន្លែ ការចិញ្ចឹមសត្វ និងដំណាំចម្រុះជុំវិញមានការកើនឡើង | ២០១៤-២០១៨ | ក្រ. កសិកម្ម<br>ដៃគូអភិវឌ្ឍ | 260,000.00 |
| ៤ | ការពង្រីកនិងការពង្រឹងសេវាអប់រំកុមារតូច | ○ ការពង្រីកសេវាអប់រំកុមារតូចគ្រប់រូបភាពនិងគ្រប់ទីកន្លែងសម្រាប់កុមារអាយុចាប់ពី ០ ដល់ក្រោម ៦ ឆ្នាំ | • ចំនួនសេវាពង្រីកនិងពង្រឹង<br>• វិសាលភាពនៃសេវាបានពង្រីក | ២០១៤-២០១៨ | ក្រ.អយក<br>ដៃគូអភិវឌ្ឍ | 4,610,920.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | | ○ ពង្រឹងនិងពង្រីកមត្តេយ្យសិក្សាសហគមន៍ពីរភាសាសម្រាប់តំបន់ជនជាតិដើមភាគតិច | • ចំនួនមត្តេយ្យសហគមន៍ពីរភាសាបានពង្រីក | ២០១៤-២០១៨ | ក្រ.អយក ដៃគូអភិវឌ្ឍ | 5,772,764.00 |
| | | ○ ពង្រីកកម្មវិធីអប់រំបញ្ចូលគ្នាសម្រាប់កុមារមានពិការភាពនៅតាមសាលាមត្តេយ្យសិក្សារដ្ឋនិងមត្តេយ្យសិក្សាសហគមន៍ | • ចំនួនកម្មវិធីអប់រំបញ្ចូលគ្នានៅក្នុងមត្តេយ្យសិក្សារដ្ឋនិងមត្តេយ្យសិក្សាសហគមន៍បានពង្រីក | ២០១៤-២០១៨ | ក្រ.អយក ដៃគូអភិវឌ្ឍ | 100,000.00 |
| | | ○ ការសាងសង់និងពង្រីកសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសិក្សាសហគមន៍ និងសាលាមត្តេយ្យសិក្សាធនធានឱ្យស្របតាមស្តង់ដារគុណភាព | • ចំនួនសាលាមត្តេយ្យសិក្សារដ្ឋ សាលាមត្តេយ្យសិក្សាសហគមន៍ និងសាលាមត្តេយ្យសិក្សាធនធានស្របតាមស្តង់ដារគុណភាពមានការកើនឡើង | ២០១៤-២០១៨ | ក្រ.អយក ដៃគូអភិវឌ្ឍ | 15,869,930.00 |
| ៥ | ការបង្កើនថវិកាចំណាយលើការគាំពារនិងអភិវឌ្ឍកុមារតូចនៅក្នុងថវិកាអភិវឌ្ឍឃុំសង្កាត់និងប្រភពផ្សេងទៀត | ○ រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការបង្កើនថវិកាសម្រាប់ការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅក្នុងថវិកាអភិវឌ្ឍឃុំសង្កាត់និងប្រភពផ្សេងទៀត<br>○ រៀបចំឡើងវិញនូវមុខងារមត្តេយ្យសិក្សាសហគមន៍ឱ្យក្លាយជាមុខងារ ជាកាតព្វកិច្ច និងធ្វើការផ្ទេរឱ្យទៅដល់រដ្ឋបាលឃុំ សង្កាត់ | • ភាគរយថវិកាសម្រាប់ការគាំពារនិងអភិវឌ្ឍន៍កុមារតូច<br>• នៅក្នុងថវិកាអភិវឌ្ឍឃុំសង្កាត់និងប្រភពផ្សេងទៀតមានការកើនឡើង<br>• មត្តេយ្យសិក្សាសហគមន៍នឹងក្លាយជាមុខងារជាកាតព្វកិច្ច | ២០១៤-២០១៨ | ក្រ.អយក ក្រ.មហាផ្ទៃ ក្រ.សេដ្ឋកិច្ច អ.គ.អ.ល. | 10,000.00 |
| ៦ | សិក្សាលទ្ធភាពក្នុងការជំរុញឱ្យរោងចក្រសហគ្រាសនិងក្រុមហ៊ុន | ○ រៀបចំលិខិតបទដ្ឋានគតិយុត្តក្រុមការងារដើម្បីសិក្សាលទ្ធភាពជំរុញឱ្យរោងចក្រ សហគ្រាស និងក្រុមហ៊ុនវិនិយោគរៀបចំសេវាគាំពារនិងអភិវឌ្ឍ | • ចំនួនរោងចក្រ សហគ្រាសនិងក្រុមហ៊ុនវិនិយោគបានរៀបចំសេវា | ២០១៤-២០១៦ | | 43,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | វិនិយោគរៀបចំសេវាគាំពារនិងអភិវឌ្ឍកុមារតូច | កុមារតូច | គាំពារនិងអភិវឌ្ឍកុមារតូច | | | |
| ៧ | ការទទួលបាននូវកម្មវិធីមត្តេយ្យសិក្សាសហគមន៍និងកម្មវិធីគាំទ្រភាពជាមាតាបិតានិងគ្រួសារ | ○ អប់រំមាតាបិតាឱ្យយល់ពីតម្លៃនិងសារៈសំខាន់នៃការគាំពារនិងអភិវឌ្ឍន៍កុមារតូចនិងការសិក្សាវ័យដំបូងរបស់កុមារ | • ចំនួនមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលអនុវត្តកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូចបានពង្រឹង<br>• ចំនួនមាតាបិតានិងអ្នកពាក់ព័ន្ធបង្កើនការយកចិត្តទុកដាក់និងយល់កាន់តែច្បាស់ពីតម្លៃនៃការអប់រំកុមារតូច | ២០១៤-២០១៨ | ក្រ.អយក.<br>ក្រ.មហាផ្ទៃ<br>ក្រ.កិច្ចការនារី<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិ វឌ្ឍ | 250,000.00 |
| ៨ | ការត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តការងារគាំពារនិងអភិវឌ្ឍកុមារតូចតាមមត្តេយ្យសិក្សាសហគមន៍ | ○ ចុះតាមខេត្តគោលដៅដើម្បីគាំទ្របច្ចេកទេសតាមដានត្រួតពិនិត្យនិងវាយតម្លៃ | • ចំនួនមត្តេយ្យសិក្សាសហគមន៍និងការអប់រំមាតាបិតានិងគ្រួសារដំណើរការទៅដោយសុវត្ថិភាពនិងប្រកបដោយគុណភាព | ២០១៤-២០១៨ | ក្រ.កិច្ចការនារី<br>ក្រ.អយក.<br>ក្រ.មហាផ្ទៃ<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិ វឌ្ឍ | 150,000.00 |

**យុទ្ធសាស្ត្រទី ៨ ៖ ធានាឱ្យគ្រប់គ្រួសារទទួលបានព័ត៌មាន និងសេវាដូចជា ទឹកស្អាតនិងអនាម័យ សុខភាព អាហារូបត្ថម្ភ ការបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់អាហារបន្ថែម ការទទួលថ្នាំបង្ការ ជីវជាតិA ជាតិដែក និងអំបិលអ៊ីយ៉ូដ ការរៀនពីដំបូង ការចុះបញ្ជីកំណើត ការទប់ស្កាត់ជំងឺឆ្លងគ្រប់ប្រភេទមានជាអាទិ៍ មេរោគអេដស៍និងជំងឺអេដស៍ ជំងឺគ្រុនចាញ់ ការការពារគ្រួសារពីអំពើហិង្សា និង ការរងគ្រោះដោយប្រការផ្សេងៗ។**

| ល.រ | យុទ្ធសាស្ត្ររង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្រប់ដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលា កំណត់ | អ្នកទទួល ខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | ការផ្តល់ព័ត៌មាននិងសេវាដល់មាតាបិតា និងកុមារ អំពីទម្លាប់អនាម័យ បរិស្ថាន អនាម័យខ្លួនប្រាណ សុខភាពនិងសុវត្ថិភាពអាហារូបត្ថម្ភ | ○ រៀបចំសារបច្ចេកទេសពាក់ព័ន្ធ<br>○ រៀបចំនិងផ្សព្វផ្សាយសារបច្ចេកទេសកសិកម្មពាក់ព័ន្ធលើអាហារូបត្ថម្ភ អនាម័យ សុខភាព និងសុវត្ថិភាពដល់មាតាបិតានិងកុមារ | • ចំនួនប្រព័ន្ធផ្សព្វផ្សាយបានផ្សព្វផ្សាយ | ២០១៤-២០១៨ | ក្រ. អ.យ.ក<br>ក្រ.កសិកម្ម<br>ក្រ.ព័ត៌មាន<br>ក្រ. អភិវឌ្ឍន៍ជនបទ<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 1,805,500.00 |
| ២ | ការផ្តល់ព័ត៌មាននិងសេវាដល់សហគមន៍អំពីទម្លាប់អនាម័យនិងកិច្ចគាំពារបរិស្ថាន | ○ រៀបចំសារបច្ចេកទេសពាក់ព័ន្ធ | • ចំនួនប្រព័ន្ធផ្សព្វផ្សាយបានផ្សព្វផ្សាយ | ២០១៤-២០១៨ | ក្រសួងអ.យ.<br>ក្រ.កសិកម្ម<br>ក្រ.ព័ត៌មាន<br>ក្រ. អភិវឌ្ឍន៍ជនបទ<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 406,400.00 |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | ការបំពាក់បរិក្ខារនិងការផ្គត់ផ្គង់ទឹកស្អាតនិងបង្គន់អនាម័យ នៅតាមសាលារៀននិងទីសាធារណៈ | ○ រៀបចំបំពាក់បរិក្ខារនិងការផ្គត់ផ្គង់ទឹកស្អាតនិងបង្គន់អនាម័យ នៅតាមសាលារៀននិងទីសាធារណៈ | • ចំនួនសាលា និងទីសាធារណៈបានទទួលរៀបចំបំពាក់បរិក្ខារ និងការផ្គត់ផ្គង់ទឹកស្អាតនិងបង្គន់អនាម័យ | ២០១៤-២០១៨ | ក្រ. អ.យ.ក<br>ក្រ.កសិកម្ម<br>ក្រ.ព័ត៌មាន<br>ក្រ. អភិវឌ្ឍន៍ជនបទ<br>ដៃគូអភិវឌ្ឍ | 412,500.00 |
| | | ○ ការរៀបចំម៉ូឌុលបណ្តុះបណ្តាលអំពីទឹកស្អាត ជម្រើសសម្រាប់សម្អាតទឹកនិងរក្សាទុកទឹកប្រកបដោយសុវត្ថិភាព | • ម៉ូឌុលបណ្តុះបណ្តាលអំពីទឹកស្អាត ជម្រើសសម្រាប់សម្អាតទឹក និងរក្សាទុកទឹកប្រកបដោយសុវត្ថិភាពបានរៀបចំ | ២០១៤-២០១៥ | ក្រ.អ.យ.ក<br>ក្រ.អភិវឌ្ឍន៍ជនបទ<br>ដៃគូអភិវឌ្ឍ | 100,000.00 |
| | | ○ ការសាងសង់និងការជួសជុលបង្គន់ជាលក្ខណៈមូលដ្ឋាន និងការផ្តល់ប្រាក់សម្រាប់សាងសង់បង្គន់អនាម័យ | • ចំនួនបង្គន់អនាម័យជាលក្ខណៈមូលដ្ឋានបានសាងសង់ | ២០១៤-២០១៨ | ក្រ.អ.យ.ក<br>ក្រ.អភិវឌ្ឍន៍ជនបទ<br>ដៃគូអភិវឌ្ឍ | 1,000,000.00 |
| ៤ | ការបង្កើនការយល់ដឹងអំពីសារៈសំខាន់និងតម្រូវការនៃការចុះសំបុត្រកំណើត | ○ រៀបចំយន្តការ ឯកសារផ្សព្វផ្សាយ<br>○ ការរៀបចំឱ្យមានឧបករណ៍សម្ភារៈសម្រាប់ផ្តល់សំបុត្រកំណើតឱ្យបានគ្រប់គ្រាន់ | • ចំនួនកុមារចុះសំបុត្រកំណើតមានការកើនឡើង | ២០១៤-២០១៨ | ក្រ.មហាផ្ទៃ<br>ក្រ.អយក<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 20,000.00 |
| | | ○ ការពង្រឹងបន្ថែមលើការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់អំពីការចុះអត្រានុកូលដ្ឋាន និងលុបបំបាត់ការប្រមូលថ្លៃសេវាក្រៅផ្លូវការ | | | | 10,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | ការធានាថាកុមារអាយុ ០ ដល់ ៦ ឆ្នាំ ដែលកំពុងរងគ្រោះបានទទួលការថែទាំ | ○ រៀបចំយន្តការប្រមូលកុមារទាំងនោះឱ្យបានទទួលសេវា | • ចំនួនកុមារបានទទួលសេវា | ២០១៤-២០១៨ | ក្រ.សង្គមកិច្ច<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 50,000.00 |
| ៦ | ការកសាងសមត្ថភាពរបស់ភ្នាក់ងារសង្គមកិច្ច មាតាបិតានិងអ្នកផ្តល់ការថែទាំតាមសហគមន៍ | ○ រៀបចំយន្តការអនុវត្ត<br>○ វគ្គបណ្តុះបណ្តាលគ្រូបង្គោលដល់សហគមន៍កសិករភ្នាក់ងារសុខភាពសត្វភូមិ, ភ្នាក់ងារផ្សព្វផ្សាយ កសិកម្មឃុំ,សហគមន៍ចិញ្ចឹមសត្វ, សហគនម៍នេសាទ, សហគមន៍ព្រៃឈើ ផ្សព្វផ្សាយបន្តដល់សហគមន៍មូលដ្ឋាន | ក្រសួងសង្គមកិច្ច មាតាបិតា និងអ្នកផ្តល់ការថែទាំតាមសហគមន៍បានទទួលការបង្កើនសមត្ថភាព | ២០១៤-២០១៨ | ក្រ.សង្គមកិច្ច<br>ក្រ.កសិកម្ម<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 433,000.00 |
| ៧ | ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ | ○ រៀបចំយន្តការអនុវត្ត | • ចំនួនអំពើហិង្សាមានការថយចុះ | ២០១៤-២០១៨ | ក្រ.មហាផ្ទៃ<br>ក្រ.សង្គមកិច្ច<br>ក្រ.កិច្ចការនារី<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 60,000.00 |
| ៨ | ការបង្កើនផ្សព្វផ្សាយការយល់ដឹងអំពីសិទ្ធិរបស់កុមារ | ○ រៀបចំយន្តការអនុវត្ត<br>○ រៀបចំសម្ភារៈផ្សព្វផ្សាយនិងចុះធ្វើការផ្សព្វផ្សាយពីសិទ្ធិកុមារដល់សហគមន៍មូលដ្ឋាន | • ចំនួនប្រព័ន្ធផ្សព្វផ្សាយបានផ្សព្វផ្សាយ | ២០១៤-២០១៨ | ក្រ.មហាផ្ទៃ<br>ក្រ. សង្គមកិច្ច<br>ក្រ.អយក.<br>ដៃគូអភិវឌ្ឍ | 45,000.00 |
| ៩ | ការរៀបចំនិងកែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ | ○ រៀបចំនិងកែលម្អលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារ<br>○ រៀបចំគោលនយោបាយគាំពារនិងអភិវឌ្ឍកុមារក្នុងវិស័យកសិកម្ម | • លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចការពារកុមារត្រូវបានកែលម្អ និងរៀបចំ | ២០១៤-២០១៨ | ក្រ.មហាផ្ទៃ<br>ក្រ.សង្គមកិច្ច<br>ក្រ.អយក.<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 35,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| ១០ | ការគាំទ្រកុមារស្ថិតក្នុងភាពអាសន្នឬគ្រោះមហន្តរាយផ្សេងៗ | ○ បង្កើតកម្មវិធីអប់រំ អាហារូបត្ថម្ភ ការថែទាំសុខភាព និងការគាំពារនានាសម្រាប់កុមារដែលស្ថិត ក្នុងភាពអាសន្ន ឬ គ្រោះមហន្តរាយផ្សេងៗ | • ចំនួនកុមារដែលទទួលផលពីគម្រោងកម្មវិធី | ២០១៤-២០១៨ | ក្រ.អយក<br>ក្រ.សុខាភិបាល<br>ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | 1,200,000.00 |

**យុទ្ធសាស្ត្រទី ៩៖ បង្កើតឱ្យមានយន្តការផ្សព្វផ្សាយព័ត៌មានអំពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច សម្រាប់ទាក់ទាញការគាំទ្រសេវាទាំងនោះ។**

| ល.រ | យុទ្ធសាស្ត្ររង កម្មវិធី សកម្មភាពគោល | កិច្ចការ និងការគ្របដណ្តប់របស់កម្មវិធី សកម្មភាព | សូចនាករ | ពេលវេលា កំណត់ | អ្នកទទួលខុសត្រូវ | ថវិកា (USD) |
|---|---|---|---|---|---|---|
| ១ | ការផ្សព្វផ្សាយព័ត៌មានអំពីការគាំពារនិងអភិវឌ្ឍកុមារតូចឱ្យបានទូលំទូលាយ ដោយប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់រូបភាពទាំងអស់រួមទាំង វិទ្យុ ទូរទស្សន៍ និងការបង្កើតគេហទំព័រ និង ប្រព័ន្ធទំនាក់ទំនងសង្គម និងព្រឹត្តិបត្តិព័ត៌មាន | ○ ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសកម្មភាពនិងរបាយការណ៍ពាក់ព័ន្ធការងារគាំពារនិងអភិវឌ្ឍកុមារតូច<br>○ សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការគាំពារនិងអភិវឌ្ឍន៍កុមារតូច<br>○ ផ្តល់ការបណ្តុះបណ្តាលនិងពង្រឹកទំនាក់ទំនងជាមួយភ្នាក់ងារសារព័ត៌មានអាជីពដើម្បីលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធការគាំពារនិងអភិវឌ្ឍន៍កុមារតូច | • ចំនួនលើកនៃការផ្សព្វផ្សាយអំពីសកម្មភាព និង របាយការណ៍ពាក់ព័ន្ធការងារគាំពារនិងអភិវឌ្ឍន៍កុមារតូចតាមគ្រប់រូបភាព | ២០១៥ | ក្រសួងព័ត៌មាន ក្រ.ពាក់ព័ន្ធ ដៃគូអភិវឌ្ឍ | 778,110.00 |
| ២ | ការបង្កើតកម្មវិធីប្រាស្រ័យទាក់ទងតាមរយៈ៖<br><br>-ការពិគ្រោះយោបល់កម្រិតនយោបាយ | ○ ជំរុញឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពពីអ្នកតាក់តែងគោលនយោបាយ | • ចំនួនលើកនៃការចូលរួមប្រកបដោយប្រសិទ្ធភាពពីអ្នកតាក់តែងគោលនយោបាយ | ២០១៥-២០១៨ | ក្រ.មហាផ្ទៃ ក្រសួងអយក. ក្រ.ពាក់ព័ន្ធ ដៃគូ អភិវឌ្ឍន៍ | 29,000.00 |
| | | ○ បង្កើនការយល់ដឹងដល់មាតាបិតា/អ្នក | • ចំនួនមាតាបិតា និង អ្នកពាក់ព័ន្ធក្នុង | ២០១៥-២០១៨ | ក្រ.មហាផ្ទៃ ក្រ.អយក | 18,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | -ប្រព័ន្ធផ្សព្វផ្សាយសង្គម<br>-វេទិកាសហគមន៍ និង<br>-ការប្រាស្រ័យទាក់ទងអន្តរបុគ្គលតាមរូបភាពផ្សេងៗ | អាណាព្យាបាល និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ | សហគមន៍ សេវាគាំពារនិងអភិវឌ្ឍកុមារតូច មានការគាំទ្រ | | ក្រ.ពាក់ព័ន្ធ<br>ដៃគូអភិវឌ្ឍ | |
| ៣ | អគ្គលេខាធិការដ្ឋានគាំពារនិងអភិវឌ្ឍកុមារតូចត្រូវធ្វើការស្រាវជ្រាវបឋម បូកសរុបលទ្ធផលវេទិកាពិគ្រោះយោបល់ | ○ ធ្វើការពិនិត្យឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយលើការអនុវត្តបច្ចុប្បន្ននៅតាមវិស័យ | • ព័ត៌មានពីបច្ចុប្បន្នភាពក្នុងការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចវិស័យពាក់ព័ន្ធត្រូវបានរៀបចំ | ២០១៥-២០១៨ | អ.គ.អ.ល.<br>ដៃគូអភិវឌ្ឍ | 16,000.00 |
| | | ○ ផ្តល់ព័ត៌មានត្រឡប់ដើម្បីដាក់បញ្ចូលអនុសាសន៍ទៅក្នុងការរៀបចំផែនការសកម្មភាពតាមវិស័យ | • ចំនួនលើកនៃការផ្តល់ព័ត៌មានត្រឡប់ដើម្បីដាក់បញ្ចូល អនុសាសន៍ទៅក្នុង ការរៀបចំផែនការសកម្មភាពតាមវិស័យ | ២០១៥-២០១៨ | អ.គ.អ.ល.<br>ដៃគូអភិវឌ្ឍ | 18,000.00 |
| | | ○ ពិនិត្យតាមដានលើដំណើរការនៃការអនុវត្តផែនការសកម្មភាពសម្រាប់ផ្តល់ការគាំទ្រនិងកៀរគរធនធានបន្ថែម | • ចំនួនលើកនៃកិច្ចប្រជុំពិនិត្យតាមដានលើដំណើរការនៃការអនុវត្តផែនការសកម្មភាព | ២០១៥-២០១៨ | គ.ជ.គ.ក.<br>ដៃគូអភិវឌ្ឍ | 50,000.00 |



# ៤. គម្រោងចំណាយ

## ៤. គម្រោងចំណាយ

## ថវិកាយុទ្ធសាស្ត្រនីមួយៗ ក្នុងចំណោមយុទ្ធសាស្ត្រទាំង ៩ ត្រូវបានបង្ហាញដូចខាងក្រោម ៖

| ល.រ | ប្រធានបទរបស់យុទ្ធសាស្ត្រ | ថវិកា (USD) |
|---|---|---|
| ១ | រៀបចំក្របខណ្ឌច្បាប់ បទដ្ឋាន និងយន្តការដើម្បីគាំទ្រនិងអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាពដោយកំណត់ឱ្យមានកិច្ចសហការ និងភារកិច្ចរបស់ភាគីពាក់ព័ន្ធសំខាន់ៗ។ | 1,132,000.00 |
| ២ | កែលម្អយន្តការតាមដានវាយតម្លៃ ដែលមានស្រាប់ ឬ បង្កើតថ្មីដោយមានការចូលរួមពីក្រសួង ស្ថាប័ន សហគមន៍ ដៃគូអភិវឌ្ឍនានា និងកែលម្អគណៈកម្មការសម្របសម្រួលបច្ចេកទេសថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដោយបែងចែកភារកិច្ច និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់។ | 200,500.00 |
| ៣ | កសាងសមត្ថភាព (បណ្តុះបណ្តាលមុននិងកំពុងបម្រើការងារ) អ្នកអនុវត្តកម្មវិធី មាតាបិតា អ្នកអាណាព្យាបាល និងអ្នកគ្រប់គ្រងថែរក្សាកុមារលើខ្លឹមសារ និងថៃទាំឱ្យស្របតាមកម្មវិធីសិក្សា និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ | 455,000.00 |
| ៤ | បង្កើតយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីផ្តល់វិញ្ញាបនបត្រឬលិខិតទទួលស្គាល់ដល់អ្នកអនុវត្តកម្មវិធីទៅតាមសេវាថែទាំជាក់ស្តែង។ | 75,000.00 |
| ៥ | បង្កើនសេវា និងការអប់រំស្តីអំពីការថែទាំសុខភាព និងអាហារូបត្ថម្ភដល់ស្ត្រីទាំងអស់ដែលមានផ្ទៃពោះ។ | 1,935,000.00 |
| ៦ | បង្កើនសេវាថែទាំព្យាបាលសុខភាព ជំងឺ ដល់កុមារតូចចាប់ពីពេលកើតដល់អាយុ៣ឆ្នាំ ដោយពិនិត្យសុខភាពជាប្រចាំ ផ្តល់ថ្នាំបង្ការទាន់ពេល និងពេញលេញ ហើយតាមដានការផ្តល់សេវាអាហារូបត្ថម្ភ មានជំងឺរ៉ាំរ៉ៃ ល្វតលាស់យឺត ពិការ។ | 1,653,989.00 |
| ៧ | ពង្រីកសេវាគាំពារ និងអភិវឌ្ឍកុមារតូចរួមមាន សេវារដ្ឋ សេវាសហគមន៍ សេវាឯកជន តាមផ្ទះ និងតាមខ្នងផ្ទះ ជាពិសេសការហាត់រៀនពីដំបូងចំពោះកុមារតូច។ | 45,012,501.00 |
| ៨ | ធានាឱ្យគ្រប់គ្រួសារទទួលបានព័ត៌មាន និងសេវាដូចជា ទឹកស្អាតនិងអនាម័យ សុខភាព អាហារូបត្ថម្ភ ការបំបៅកូនដោយ ទឹកដោះម្តាយ ការផ្តល់អាហារបន្ថែម ការទទួលថ្នាំបង្ការជីវជាតិអា ជាតិដែក និងអំបិលអ៊ីយ៉ូដ ការរៀនពីដំបូង ការចុះបញ្ជីកំណើត ការទប់ស្កាត់ជំងឺឆ្លងគ្រប់ប្រភេទ មានជាអាទិ៍ មេរោគអេដស៍និងជំងឺអេដស៍ ជំងឺគ្រុនចាញ់ ការការពារគ្រួសារពីអំពើហិង្សា និងការរងគ្រោះដោយប្រការផ្សេងៗ។ | 5,164,900.00 |
| ៩ | បង្កើតឱ្យមានយន្តការផ្សព្វផ្សាយព័ត៌មានអំពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចសម្រាប់ទាក់ទាញការគាំទ្រសេវាទាំងនេះ។ | 909,110.00 |
| **សរុប** | | **56,538,000.00** |



# ៥.ការប្រមូលធនធាន
# គាំទ្រការអនុវត្តផែនការសកម្មភាព

## ៥.ការប្រមូលធនធានគាំទ្រការអនុវត្តផែនការសកម្មភាព

### ៥.១ នីតិវិធីនៃការប្រមូលធនធាន

ការអនុវត្តផែនការសកម្មភាពក្នុងរយៈពេល ២០១៤ ដល់ ២០១៨ ធនធានប្រមាណ ៥៥,៤៧០,៥០០.០០ ដុល្លារនឹងត្រូវរំពឹងទុកសម្រាប់គាំទ្រការអនុវត្ត។ ការប្រមូលធនធានអាចមានរូបភាព ៖

**ថវិកាគាំទ្រ៖** ធនធាននឹងត្រូវផ្ទេរនិងដាក់បញ្ចូលជាមួយនឹងថវិការបស់រាជរដ្ឋាភិបាល និងប្រើប្រាស់ប្រព័ន្ធការងារដែលមានស្រាប់។ សកម្មភាពនឹងផ្តោតលើអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្ររបស់វិស័យនីមួយៗ

**មូលនិធិភាពជាដៃគូ៖** ធនធាននឹងត្រូវប្រមូលផ្តុំគាំទ្រដល់សកម្មភាពដែលផ្តោតលើក្រុមគោលដៅនិងវិសាលភាពប្រហាក់ប្រហែលគ្នា។ ដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធត្រូវឯកភាព និងគាំទ្របំពេញបន្ថែមទៅលើសកម្មភាព ឬ អាទិភាព ស្របនឹងផែនការយុទ្ធសាស្ត្ររបស់វិស័យនីមួយៗ។ នីតិវិធីអនុវត្តនឹងត្រូវកំណត់ ឬ ប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាល។

**គម្រោងដាច់ដោយឡែក៖** ធនធាននឹងត្រូវផ្តោតលើអន្តរាគមន៍ឬសកម្មភាព អាទិភាព ឬបន្ទាប់បន្សំដែលសេវារបស់រាជរដ្ឋាភិបាលមិនទាន់អាចទៅដល់។ ធនធាននឹងត្រូវគ្រប់គ្រងការអនុវត្តដោយផ្ទាល់ដៃគូអភិវឌ្ឍ ឬ អង្គការមិនមែនរដ្ឋាភិបាល។

ក្នុងរយៈពេលខ្លី ស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងពាក់ព័ន្ធនឹងត្រូវទទួលខុសត្រូវអនុវត្តកម្មវិធី ឬ សកម្មភាពដែលកំពុងដំណើរការបច្ចុប្បន្ន។ ក្នុងពេលអនាគតស្របតាមកំណែទម្រង់ការគ្រប់គ្រងតាមបែបវិមជ្ឈការនិងវិមជ្ឈការ ផែនការសកម្មភាពនឹងត្រូវពិនិត្យឡើងវិញ ដោយពិនិត្យមើលលើការទទួលខុសត្រូវ ការសម្របសម្រួល និងការសិក្សាផ្ទេរធនធាននិងការទទួលខុសត្រូវឱ្យទៅដល់ថ្នាក់ក្រោមជាតិ។

### ៥.២ ការចូលរួមនិងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ

ក្នុងដំណាក់កាល ២០១៤ ដល់ ២០១៨ ការចូលរួមនិងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធត្រូវបានរំពឹងទុកដូចខាងក្រោម ៖

**រាជរដ្ឋាភិបាលកម្ពុជា៖** ទទួលបន្ទុកក្នុងការផ្តល់សេវាពាក់ព័ន្ធ ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញជាពិសេសដំណើរការស្ថាប័ន និងអង្គភាពស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ដូចជាសាលាមត្តេយ្យសិក្សាសាធារណៈ បៀវត្សគ្រូមត្តេយ្យសិក្សា ការបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា។

**ក្រុមប្រឹក្សាឃុំ សង្កាត់៖** ក្នុងបរិបទនៃវិមជ្ឈការនិងវិសហមជ្ឈការ មូលនិធិវិនិយោគឃុំសង្កាត់នឹងត្រូវគាំទ្រដល់សេវាពាក់ព័ន្ធនឹងការគាំពារនិងអភិវឌ្ឍន៍កុមារតូច។

**ដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាល៖** ការគាំទ្រដល់គំនិតផ្តួចផ្តើមថ្មីៗ ការសិក្សាពិសោធន៍ អន្តរាគមន៍ដោយឡែក និងសកម្មភាពពាក់ព័ន្ធដទៃទៀត។

រាល់កម្មវិធីនិងសកម្មភាពអនុវត្តដោយក្រសួងពាក់ព័ន្ធ នឹងត្រូវឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រនិងផែនការប្រតិបត្តិប្រចាំឆ្នាំនៅតាមវិស័យពាក់ព័ន្ធនីមួយៗ ដើម្បីធានាឱ្យមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្ត។



# ៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

## ៦. ការពិនិត្យតាមដាន និងការវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃលើគោលនយោបាយស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងផែនការសកម្មភាពជាតិរបស់គោលនយោបាយនឹងធានាយ៉ាងណាឱ្យគោលនយោបាយនេះអាចបំពេញបានតាមគោលបំណងរបស់ខ្លួន និងសម្រេចបាននូវលទ្ធផលរំពឹងទុក។ លើសពីនេះ គួរមានការកំណត់និងអនុវត្តគម្រោងស្រាវជ្រាវដែលចាត់ទុកជាអាទិភាពខ្ពស់មួយចំនួន ក្រោមគោលនយោបាយ និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូចនេះ។

ក្រសួងវិស័យពាក់ព័ន្ធការគាំពារនិងអភិវឌ្ឍន៍កុមារតូចត្រូវរៀបចំប្រព័ន្ធ ឬ យន្តការពិនិត្យតាមដាននិងវាយតម្លៃលើកម្មវិធី ឬ សេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមវិស័យរៀងៗខ្លួនដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃសេវានីមួយៗ។

### ការពិនិត្យផលប៉ះពាល់

ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច មានការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិក្នុងឆ្នាំ ២០១៦ និងពិនិត្យឡើងវិញចុងក្រោយឆ្នាំ ២០១៨ ដើម្បីវាយតម្លៃផលប៉ះពាល់នៃការអនុវត្តទាំងមូល។ ការវាយតម្លៃពាក់កណ្តាលអាណត្តិ និងចុងក្រោយនឹងត្រូវចូលរួមតាមរយៈរបាយការណ៍វាយតម្លៃឯករាជ្យ។ ការពិនិត្យឡើងវិញនឹងត្រូវគ្រប់គ្រងដោយគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច ដែលត្រូវពិនិត្យឡើងវិញនូវហេតុផលនៃគុណភាពនិងប្រសិទ្ធភាពកម្មវិធី យុទ្ធសាស្ត្រក្នុងការរួមចំណែកសម្រេចការអនុវត្តគោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច។

### ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាព

ការប្រជុំបូកសរុបលទ្ធផលការងារពាក់កណ្តាលឆ្នាំ និងការប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំត្រូវបានរៀបចំជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ ក្នុងគោលបំណងពិនិត្យវឌ្ឍនភាពនៃសូចនាករលទ្ធផលដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនីមួយៗ។ ក្រសួង វិស័យពាក់ព័ន្ធត្រូវរៀបចំរបាយការណ៍លទ្ធផលតាមយុទ្ធសាស្ត្រ និងកម្មវិធីនីមួយៗជូន គ.ជ.គ.ក. ដើម្បីបូកសរុបនិងរៀបចំការប្រជុំពិនិត្យលទ្ធផលរួមគ្នាមុននឹងរាយការណ៍ពីវឌ្ឍនភាពរួមជូនរាជរដ្ឋាភិបាល នាពាក់កណ្តាលឆ្នាំ និងចុងឆ្នាំនីមួយៗចាប់តាំងពី ឆ្នាំ ២០១៤ ដល់ ២០១៨។

### ការពិនិត្យតាមដានការអនុវត្តកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូចតាមវិស័យ

ក្រសួងពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូច ឬ ផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចត្រូវរៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដើម្បីវាយតម្លៃផលប៉ះពាល់នៃកម្មវិធីនីមួយៗតាមវិស័យ និងពិនិត្យតាមដានការអនុវត្តការផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិនិងថ្នាក់សេវាផ្ទាល់។ ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃតាមវិស័យត្រូវផ្សារភ្ជាប់ជាមួយ

ផែនការនៃការចុះពិនិត្យតាមដាន ការផ្តល់និងបញ្ជូនរបាយការណ៍ ព្រមទាំងទម្រង់ពាក់ព័ន្ធនៃសកម្មភាពចុះពិនិត្យតាមដានលើលទ្ធផលនៃសេវានីមួយៗ។

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច សម្របសម្រួលយន្តការនៃការពិនិត្យតាមដាននិងវាយតម្លៃតាមវិស័យនីមួយៗ ព្រមទាំងសម្របសម្រួលក្នុងការប្រមូលរបាយការណ៍លទ្ធផលអនុវត្តកម្មវិធីផ្តល់សេវាគាំពារនិងអភិវឌ្ឍកុមារតូចទាំងអស់ និងរបាយការណ៍នៃការពិនិត្យតាមដាននិងវាយតម្លៃតាមវិស័យ ជាពិសេសសម្របសម្រួលការរៀបចំរាល់ការប្រជុំពិនិត្យលទ្ធផល និងពិនិត្យផលប៉ះពាល់ក្នុងការអនុវត្តផែនការសកម្មភាព និងគោលនយោបាយគាំពារនិងអភិវឌ្ឍកុមារតូច។

លើសពីនេះទៀតកម្មវិធីគាំពារនិងអភិវឌ្ឍកុមារតូចដែលគាំទ្រដោយដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល អង្គការស៊ីវិល និងវិស័យឯកជននឹងត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដោយគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍកុមារតូច។ អន្តរាគមន៍អ្នកទាំងនោះអាចនឹងផ្តល់គំរូល្អលើការគាំពារ និងអភិវឌ្ឍកុមារតូចប្រកបដោយភាពច្នៃប្រឌិតនិងការរួមបញ្ចូលគ្នាបន្ថែមទៀតសម្រាប់ប្រទេសកម្ពុជា។ បទពិសោធន៍ពីការអន្តរាគមន៍ទាំងនោះគួរត្រូវបានចងក្រងជាឯកសារ ត្រឹមត្រូវ និងបានពិនិត្យនៅក្នុងលក្ខខណ្ឌនៃផលប៉ះពាល់ ប្រសិទ្ធិភាពក្នុងការសំរបសំរួលអន្តរវិស័យ ប្រសិទ្ធភាពចំណាយ និងការកំណត់មាត្រដ្ឋាននៃការចំណាយច្បាស់លាស់ ដើម្បីឱ្យរដ្ឋាភិបាលអាចពង្រីកសេវាទាំងនេះស្របតាមលទ្ធភាព និងសមត្ថភាពរបស់ខ្លួន។

## ការរៀបចំឯកសារឧបសម្ព័នផែនការសកម្មភាពជាត

សូចនាករបែបជាតួលេខ ចំណុចដៅលំអិតតាមឆ្នាំនីមួយៗ ផែនការថវិកាលំអិតតាមកម្មវិធី និងការកំណត់សកម្មភាពជាអាទិភាពតាមវិស័យពាក់ព័ន្ធ នឹងត្រូវរៀបចំដែលជាឯកសារឧបសម្ព័នភ្ជាប់សម្រាប់ធ្វើការតាមដានលទ្ធផលដែលបានអនុវត្ត និងសម្រាប់វិភាគក្នុងការរៀបចំផែនការបន្តឬផែនការលម្អិតតាមឆ្នាំនីមួយៗក្នុងវិស័យពាក់ព័ន្ធ។

| របៀបនៃការពិនិត្យតាមដាន | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|
| • ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ | ២០១៦ | គ.ជ.គ.ក. |
| • ការពិនិត្យឡើងវិញចុងអាណត្តិ | ២០១៨ | គ.ជ.គ.ក. |
| • វឌ្ឍនភាពនៃការគាំពារនិងអភិវឌ្ឍន៍កុមារតូចតាមវិស័យ | ២ដងក្នុង១ឆ្នាំ | អគ្គលេខាធិកាគ.ជ.គ.ក.<br>គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសតាមវិស័យ |
| • វឌ្ឍនភាពនៃការអនុវត្តកម្មវិធី ឬ សេវាគាំពារនិងអភិវឌ្ឍកុមារតូចតាមវិស័យ | ៤ដងក្នុង១ឆ្នាំ | អគ្គលេខាធិកាគ.ជ.គ.ក<br>គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសតាមវិស័យ |



# ៧. សេចក្តីសន្និដ្ឋាន

## ៧. សេចក្តីសន្និដ្ឋាន

នៅក្នុងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចនេះ ជាការសំខាន់បំផុតដែលត្រូវមានការផ្តោតការយកចិត្តទុកដាក់ជាបឋមលើយុទ្ធសាស្ត្រទី ១ ដើម្បីបង្កើតឱ្យបានឆាប់រហ័សនូវគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច គណៈកម្មាធិការជាតិសម្របសម្រួលបច្ចេកទេសកុមារតូច និងអគ្គលេខាធិការដ្ឋានគាំពារនិងអភិវឌ្ឍន៍កុមារតូច សម្រាប់អនុវត្តផែនការសកម្មភាពជាតិនេះ។ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូចមានតួនាទីសំខាន់នៅក្នុងការផ្តល់ការណែនាំ ការសម្របសម្រួល និងការអនុវត្តសកម្មភាពសំខាន់ៗដែលពាក់ព័ន្ធជាមួយនឹងការគាំពារ និងការអភិវឌ្ឍកុមារតូច។

ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច ផ្តោតជាសំខាន់លើសកម្មភាពអភិវឌ្ឍ ដែលជួយដល់ការរៀបចំផែនការអំពីសេវាគាំពារ និងអភិវឌ្ឍកុមារតូចនាពេលអនាគត។ រាជរដ្ឋាភិបាល និងដៃគូអន្តរជាតិនានា ត្រូវតែបង្កើនការវិនិយោគរបស់ខ្លួនលើការងារគាំពារនិងអភិវឌ្ឍន៍កុមារតូច នៅក្នុងរយៈពេលដំបូងនេះ ជាពិសេសការវិនិយោគទាំងនេះត្រូវផ្តោតការយកចិត្តទុកដាក់លើសកម្មភាពអភិវឌ្ឍន៍។ សកម្មភាពអភិវឌ្ឍន៍នានាត្រូវផ្តោតលើ៖ ការរៀបចំការធ្វើតេសនៅមូលដ្ឋាន និងការធានាយ៉ាងណាឱ្យកម្មវិធីសិក្សាឯកសារ សៀវភៅណែនាំ វិធីសាស្ត្រ និងមធ្យោបាយអប់រំនានា មានភាពសមស្របទៅតាមវប្បធម៌ និងទៅតាមភាសាការរៀបចំការសាកល្បង និងការវាយតម្លៃលើសេវាគាំពារ និងអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព និងការអនុវត្តការសិក្សាសំខាន់ៗមួយចំនួនតូច ដែលនឹងគាំទ្រដល់ការរៀបចំកម្មវិធីនាពេលអនាគត។

ស្របទៅតាមផែនការបច្ចុប្បន្នរបស់ក្រសួង និងដៃគូអភិវឌ្ឍអន្តរជាតិនានា សេវាដែលកំពុងមានមួយចំនួនត្រូវបានជ្រើសរើស ដើម្បីធ្វើការកែលម្អ និងពង្រីកបន្ថែមទៀត។ សេវាទាំងនេះរួមមាន៖ ការអប់រំអំពីអ្វីដែលត្រូវធ្វើ ដើម្បីត្រៀមមានផ្ទៃពោះ ការថែទាំផ្ទៃពោះ និងអាហារូបត្ថម្ភការសម្រាលកូនដោយឆ្មបជំនាញ និងការចុះសំបុត្រកំណើត សេវាការពារ និងសេវាសមាហរណកម្មនៃការពិនិត្យ និងការព្យាបាលជំងឺកុមារ តាមសហគមន៍សម្រាប់កុមារបន្ទាប់ពីពេលចាប់កំណើតរហូតដល់អាយុ ៣ ឆ្នាំ សេវាគាំពារ និងអភិវឌ្ឍកុមារតូច សេវាសិទ្ធិកុមារ សេវាការពារកុមារ សេវាអនាម័យ បរិស្ថាន និងអនាម័យខ្លួនប្រាណ។

នៅក្នុងរយៈពេល ៥ ឆ្នាំ នៃផែនការសកម្មភាពជាតិស្តីពីការគាំពារ និងការអភិវឌ្ឍន៍កុមារតូចទី ១ នេះ សេវាគាំពារ និងអភិវឌ្ឍកុមារតូចថ្មីៗមួយចំនួនតូចនឹងត្រូវរៀបចំឡើងដើម្បីបំពេញគម្លាតនៃសេវាសំខាន់ៗជាពិសេស៖

- សេវាអប់រំអំពីការថែទាំផ្ទៃពោះ ដែលនឹងបំពេញបន្ថែម និងពង្រីកសេវាថែទាំផ្ទៃពោះ និងអាហារូបត្ថម្ភបន្ថែមទៀត

- កញ្ចប់អប់រំមាតាបិតានៅថ្នាក់ជាតិ ដែលមានដាក់បញ្ចូលគ្រប់ផ្នែកទាំងអស់នៃសេវាគាំពារ និង អភិវឌ្ឍកុមារតូចដូចជា សុខភាព អាហារូបត្ថម្ភ ការអភិវឌ្ឍកុមារតូច ការអប់រំកម្រិតមត្តេយ្យសិក្សា អនាម័យបរិស្ថាន/អនាម័យខ្លួនប្រាណ សិទ្ធិកុមារ និងកិច្ចការពារកុមារ
- សេវាអន្តរាគមន៍ទាន់ពេលវេលាសម្រាប់កុមារតូចសម្រាប់កុមារដែលមានបញ្ហាអភិវឌ្ឍន៍យឺតយ៉ាវ បញ្ហាកង្វះអាហារូបត្ថម្ភ និងបញ្ហាពិការភាព គួបផ្សំជាមួយនឹងការអប់រំមាតាបិតា
- សកម្មភាពអន្តរកាល សម្រាប់កុមារ មាតាបិតា និងគ្រូ មកពីផ្ទះ ឬ សាលាមត្តេយ្យ ទៅសាលាបឋមសិក្សានៅអាយុចូលរៀនរំពឹងទុក។

សេវាទាំងនេះនឹងត្រូវសាកល្បង ហើយវាយតម្លៃក្នុងគោលបំណងធ្វើការពង្រីកការគ្របដណ្តប់របស់សេវាទាំងនេះនៅទូទាំងប្រទេស។